ព្រឹត្តិបត្រព័ត៌មានវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងកម្ពុជា

International Labour Organization

លេខ 5 | មករា 2017

# ការវិវឌ្ឍថ្មីៗនៃគោលនយោបាយពាណិជ្ជកម្ម និងភាពពាក់ព័ន្ធដែលអាចមាន សម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជា

## ផ្នែកទី I – ការវិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម

### 1. សេចក្តីផ្តើម

**វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ការវិវឌ្ឍនៅក្នុងគោលនយោបាយពាណិជ្ជកម្ម ទាំងក្នុងពេលថ្មីៗ និងតាមការរំពឹងទុក អាចមានផលប៉ះពាល់យ៉ាងខ្លាំងមកលើវិស័យនេះ។ ជាលទ្ធផល ការវិវឌ្ឍនេះនឹងប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា និងប្រាក់ឈ្នួល និងលក្ខខណ្ឌការងាររបស់កម្មករនិយោជិត។**

ការចេញផ្សាយលើកទីប្រាំនៃព្រឹត្តិបត្រព័ត៌មានរបស់អង្គការអន្តរជាតិខាងការងារ ស្តីពីវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជា ពិនិត្យមើលភាពពាក់ព័ន្ធដែលអាចមាននៃការវិវឌ្ឍគោលនយោបាយពាណិជ្ជកម្មថ្មីៗរួមមាន ការដកខ្លួនចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប ការរំកិលចេញរបស់កម្ពុជាពីស្ថានភាព "ប្រទេសដែលមានការអភិវឌ្ឍតិចបំផុត" (LDC) ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងភាពប្រសើរនៃការនាំទៅកាន់ទីផ្សារសហរដ្ឋអាមេរិកនូវប្រភេទទំនិញសម្រាប់ធ្វើដំណើរ (travel goods) ពីកម្ពុជា ។

ផ្នែកទី I ផ្តោតលើភាពពាក់ព័ន្ធនៃការវិវឌ្ឍផ្នែកគោលនយោបាយទាំងនេះ រីឯផ្នែកទី II រួមមានព័ត៌មានបច្ចុប្បន្នភាពជាទៀងទាត់អំពីស្ថិតិសំខាន់ៗទាក់ទងទៅនឹងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅក្នុងប្រទេសកម្ពុជា។[1]

### 2. សារៈសំខាន់នៃវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងចំពោះសេដ្ឋកិច្ចកម្ពុជា

នៅក្នុងឆ្នាំ 2015 តម្លៃបន្ថែមរបស់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង តំណាងឱ្យប្រមាណ 11 ភាគរយនៃសេដ្ឋកិច្ចកម្ពុជា ហើយរួមចំណែកជិតពីរភាគរយក្នុងចំណោម 7 ភាគរយនៃកំណើនផសស របស់ប្រទេស។[2] ការអភិវឌ្ឍវិស័យនេះត្រូវបានជំរុញដោយការនាំចេញ ដោយពឹងផ្អែកយ៉ាងខ្លាំងទៅលើទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ កាលពីឆ្នាំកន្លងទៅ ប្រមាណ 80 ភាគរយនៃការនាំចេញទំនិញសរុបរបស់កម្ពុជា គឺជាផលិតផលសម្លៀកបំពាក់ និងស្បែកជើង ហើយនាំចេញជាចម្បងគឺទៅកាន់ទីផ្សារសហភាពអឺរ៉ុប (43 ភាគរយ) និង សហរដ្ឋអាមេរិក (29 ភាគរយ)។[3]

វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជា បានរីកលូតលាស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ដោយចាប់ផ្តើមពី 80 លានដុល្លារសហរដ្ឋអាមេរិកនៃតម្លៃនាំចេញក្នុងឆ្នាំ 1996 រហូតដល់ 6.8 ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ 2015។ វិស័យនេះគឺជាមូលដ្ឋានចម្បងនៃសេដ្ឋកិច្ចរបស់ប្រទេស ដោយរកចំណូលបានរាប់ពាន់លានដុល្លារនៃរូបិយបណ្ណបរទេស ផ្តល់ការងារដល់កម្មកររាប់សែននាក់ (87 ភាគរយជាស្ត្រី)[4] ព្រម

---

[1] ការវិភាគនៅក្នុងព្រឹត្តិបត្រព័ត៌មាននេះគឺផ្អែកលើ ស្ថិតិផ្លូវការពីប្រភពផ្លូវការផ្សេងៗ រួមទាំងគណៈកម្មការអឺរ៉ុប (Eurostat), UNCTAD, ក្រសួងពាណិជ្ជកម្មរបស់កម្ពុជា ក្រសួងការងារ និងបណ្តុះវិជ្ជាជីវៈ គណៈកម្មាធិការវិនិយោគកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករ វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា។ ILO សូមទទួលស្គាល់ និងថ្លែងអំណរគុណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម គណៈកម្មាធិការវិនិយោគកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករ វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា ដែលបានគាំទ្រ និងផ្តល់ទិន្នន័យនៅក្នុងការបោះពុម្ពផ្សាយនេះ។ រាល់កំហុសផ្សេងទៀតគឺប្រើសន្មត់ថាជារបស់ ILO។

[2] វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា

[3] អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា (GDCE)

[4] កំណត់ត្រាស្ថិតិរបស់ក្រសួងពាណិជ្ជកម្មស្តីពីកម្លាំងការងារសំលៀកបំពាក់ និងស្បែកជើង (មិថុនា 2016)

ទាំងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ។[5]

**រូបទី 1: សមាសភាពនៃកំណើន ផសស តាមវិស័យជាតម្លៃពិតរបស់កម្ពុជា (ភាគរយ)**




* ការព្យាករបស់ IMF (មាត្រា IV IMF របាយការណ៍លេខ 16/340, វិច្ឆិកា 2016) និងវិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា (NIS)
ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា, IMF និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ការផ្លាស់ប្តូរផ្នែកគោលនយោបាយពាណិជ្ជកម្ម ដែលប៉ះពាល់ដល់ការនាំចេញសម្លៀកបំពាក់អាចមានភាពពាក់ព័ន្ធយ៉ាងខ្លាំងសម្រាប់សេដ្ឋកិច្ចកម្ពុជា។ ការវិវឌ្ឍថ្មីៗចំនួនបីអាចមានផលប៉ះពាល់លើវិស័យនេះជាវិជ្ជមាន ឬអវិជ្ជមាន។ ការវិវឌ្ឍទាំងនេះ រួមមាន៖

ក. គម្រោងដកខ្លួនចេញរបស់ចក្រភពអង់គ្លេស ពីសហភាពអឺរ៉ុប (“Brexit”)

ខ. ការដំឡើងស្ថានភាពសេដ្ឋកិច្ចកម្ពុជាពី LDC ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និង

គ. ការសម្រេចរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ក្នុងការផ្តល់ដល់កម្ពុជានូវការចូលទីផ្សាររបស់ខ្លួនដោយអនុគ្រោះ គ្មានពន្ធនាំចូលសម្រាប់ទំនិញធ្វើដំណើរ ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2016 តទៅ។

## ក. គម្រោងដកខ្លួនចេញរបស់ចក្រភពអង់គ្លេស ពីសហភាពអឺរ៉ុប (“Brexit”)

ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប អាចមានផលប៉ះពាល់អវិជ្ជមានមកលើវិស័យនាំចេញ និងសេដ្ឋកិច្ចរបស់កម្ពុជា។ ផលប៉ះពាល់អវិជ្ជមានទាំងនេះអាចកើតឡើងដោយសារៈ

i) ការធ្លាក់ចុះនូវអត្រាប្តូរប្រាក់តម្លៃពិតរបស់ចក្រភពអង់គ្លេស ធៀបនឹងដុល្លារអាមេរិកមានន័យថា អ្នកប្រើប្រាស់ជនជាតិអង់គ្លេសចំណាយលើទំនិញនាំចូលរួមទាំងផលិតផលសំលៀកបំពាក់និងស្បែកជើងដែលផលិតនៅកម្ពុជាអាចធ្លាក់ចុះ ហើយ

ii) ក្រោយពេលចាកចេញពីសហភាពអឺរ៉ុប ចក្រភពអង់គ្លេសអាចមិនរក្សានូវការផ្តល់ភាពអនុគ្រោះកម្រិតដដែលនៃការនាំចេញទំនិញរបស់កម្ពុជា។

### *សារៈសំខាន់នៃទីផ្សារអឺរ៉ុបសម្រាប់កម្ពុជា*

សហភាពអឺរ៉ុប គឺជាទីផ្សារនាំចេញដ៏ធំបំផុតរបស់កម្ពុជាដោយស្រូបយកប្រមាណជិតពាក់កណ្តាល (45 ភាគរយ) នៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជា ក្នុងអំឡុងឆមាសទីមួយនៃឆ្នាំ 2016។[6] សហភាពអឺរ៉ុបបានក្លាយជាទីផ្សារធំបំផុតសម្រាប់ការនាំចេញរបស់វិស័យក្នុងឆ្នាំ 2014 ដោយមានតម្លៃលើសទីផ្សារសហរដ្ឋអាមេរិកជាលើកដំបូង ដែលមិនធ្លាប់មានកន្លងមក។ សារៈសំខាន់នៃទីផ្សារសហភាពអឺរ៉ុបកំពុងកើនឡើង (មើលរូបទី 2) ដោយក្នុងនោះការនាំចេញសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប កើនឡើងពី 645 លានដុល្លារអាមេរិកក្នុងឆ្នាំ 2009 ដល់ 2.9 ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ 2015។ កំណើននេះមួយផ្នែកគឺដោយសារប្រព័ន្ធអនុគ្រោះ "គ្រប់យ៉ាងលើកលែងតែអាវុធ" និងការបន្ធូរបន្ថយ "វិធានប្រភពដើម"។[7]

---

[5] របាយការណ៍រួម ក្រសួងពាណិជ្ជកម្មនៃកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជា៖ ការដោះស្រាយកត្តាប្រឈមនៃបរិយាកាសក្រោយកូតា (តុលា 2004 p. iii)

[6] អគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា (GDCE).

[7] ព័ត៌មានពីគេហទំព័រក្រសួងពាណិជ្ជកម្មកម្ពុជា។ មានអនឡាញតាមគេហទំព័រ៖ http://www.moc.gov.kh/en-us/faqs/catid/5/contentid/14

តារាងទី ១៖ ចំណែកការនាំចូលផលិតផលសម្លៀកបំពាក់ និងស្បែកជើង របស់សហភាពអឺរ៉ុប ពីកម្ពុជា (តាមប្រទេសដែលបានជ្រើសរើស គិតជាភាគរយ)

| | 2000 | 2005 | 2010 | 2015 | H1 2016 |
|---|---|---|---|---|---|
| ចក្រភពអង់គ្លេស | 30.1% | 24.3% | 28.0% | 27.2% | 24.3% |
| អាល្លឺម៉ង់ | 31.0% | 50.1% | 24.5% | 22.1% | 20.4% |
| ហូឡង់ដ៏ | 7.1% | 4.0% | 15.3% | 12.6% | 12.0% |
| អេស្ប៉ាញ | 2.7% | 6.2% | 9.2% | 10.5% | 12.4% |
| បារាំង | 11.6% | 5.8% | 4.2% | 8.4% | 10.5% |
| អ៊ីតាលី | 0.7% | 1.3% | 6.7% | 7.8% | 7.2% |
| បែលហ្ស៊ីក | 3.9% | 2.3% | 6.0% | 3.8% | 5.3% |
| ស៊ុយអែត | 4.5% | 2.0% | 1.9% | 1.4% | 1.4% |
| ផ្សេងទៀត | 8.4% | 4.0% | 4.2% | 6.2% | 6.5% |
| សហភាពអឺរ៉ុបសរុប 28 | 100% | 100% | 100% | 100% | 100% |
| o/w Euro19 | 63.1% | 73.3% | 68.8% | 69.2% | 71.7% |

ប្រភព៖ ស្ថិតិអឺរ៉ុប (EuroStat) (ដកស្រង់ចេញកាលពីថ្ងៃ ១៨ តុលា ២០១៦)

ទីផ្សារចក្រភពអង់គ្លេស គឺជាសមាសភាគដ៏សំខាន់បំផុតនៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប។[8] នៅក្នុងចំណោមប្រទេសជាសមាជិករបស់សហភាពអឺរ៉ុបទាំង 28 ចក្រភពអង់គ្លេសគឺជាអ្នកទិញធំជាងគេនៃផលិតផលនាំចេញរបស់កម្ពុជាចាប់ពីឆ្នាំ 2010 មក។ ប្រទេសនេះតែមួយបានស្រូបយកជិតមួយភាគបីនៃផលិតផលនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបទាំងមូល កាលពីឆ្នាំកន្លងទៅ។ ទីផ្សារចក្រភពអង់គ្លេសមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ផលិតផលនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា។

[8] EUROSTAT នៃគណៈកម្មការអឺរ៉ុប។

រូបទី 2: ផលិតផលនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា ទៅកាន់ទីផ្សារធំៗរបស់ខ្លួន (2000-2015)




ប្រភព៖GDCE ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *កិច្ចព្រមព្រៀងពាណិជ្ជកម្មបច្ចុប្បន្នរបស់កម្ពុជាជាមួយសហភាពអឺរ៉ុប*

ប្រព័ន្ធអនុគ្រោះ "គ្រប់យ៉ាងលើកលែងតែអាវុធ" របស់សហភាពអឺរ៉ុប (EBA) ផ្តល់ដល់ប្រទេសដែលមានការអភិវឌ្ឍតិចបំផុតចំនួន 49 តាមចំណាត់ថ្នាក់របស់អង្គការសហប្រជាជាតិ នូវការចូលទៅកាន់ទីផ្សារសហភាពអឺរ៉ុបដោយគ្មានពន្ធនាំចូលនិងគ្មានកូតាសម្រាប់ការនាំចេញផលិតផលទាំងអស់ លើកលែងតែអាវុធនិងគ្រាប់រំសេវ។[9] កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសទាំង 49 ទាំងនេះ។ "គ្រប់យ៉ាងលើកលែងតែអាវុធ" គឺជាផ្នែកមួយនៃ "ប្រព័ន្ធអនុគ្រោះទូទៅ" របស់សហភាពអឺរ៉ុប និងជាគម្រោងដ៏សំខាន់មួយដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍ លើកស្ទួយសេដ្ឋកិច្ចរបស់ខ្លួន ដោយផ្តល់ដល់ពួកគេ នូវភាពអនុគ្រោះផ្នែកពន្ធនាំចូលនៅពេលលក់ទៅកាន់ទីផ្សារសហភាពអឺរ៉ុប។ ក្នុងនាមជាសមាជិកមួយនៃសហភាពអឺរ៉ុប អង់គ្លេសពង្រីកការទិញផលិតផលសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាដោយគ្មានពន្ធនាំចូលក្រោមគម្រោង EBA។

[9] គម្រោង EBA ត្រូវបានអនុម័តដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា EU 416/2001, ដោយចូលជាធរមានចាប់ពីថ្ងៃទី 5 ខែមីនា ឆ្នាំ 2001 (http://www.moc.gov.kh/en-us/faqs/catid/5/contentid/14),

**តារាងទី 2: ប្រទេសទទួលផលពី EBA នៅក្នុងតំបន់អាស៊ី និងប្រទេសមិនបានទទួលផលពី EBA មួយចំនួននៅក្នុងតំបន់អាស៊ី (ចាត់ទុកថាជាគូប្រកួតប្រជែងរបស់កម្ពុជា)៖**

| ប្រទេសទទួលផលពី EBA ក្នុងតំបន់អាស៊ី | ប្រទេសមិនបានទទួលផល EBA ក្នុងតំបន់អាស៊ី |
|---|---|
| អាហ្វហ្គានីស្ថាន | ចិន |
| បង់ក្លាដែស | ឥណ្ឌូនេស៊ី* |
| ប៊ូតាន | ថៃ |
| កម្ពុជា | វៀតណាម* |
| ឡាវ | |
| មីយ៉ាន់ម៉ា[10] | |
| នេប៉ាល់ | |
| ទីម័រ | |

ប្រភព៖ គណៈកម្មការអឺរ៉ុប

http://trade.ec.europa.eu/doclib/docs/2014/october/tradoc_152839.pdf

* មានសិទ្ធិទទួលបានកិច្ចព្រមព្រៀងទូទៅ GSP របស់សហភាពអឺរ៉ុប (GSP ស្តង់ដារ) ដែលផ្តល់ការកាត់បន្ថយពន្ធនាំចូលសម្រាប់ ca. 66% នៃខ្ទង់ពន្ធនាំចូល EU ទាំងអស់ សម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប ឬប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ដែលមិនបានទទួលអត្ថប្រយោជន៍ពីការចូលទីផ្សារអឺរ៉ុបដោយផ្អែកលើប្រព័ន្ធអនុគ្រោះផ្សេងទៀត។ ចិន និងថៃ បានរំកិលចេញពីគម្រោង Standard GSP នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2015។

មានប្រទេសមួយចំនួនទៀតនៅក្នុងតំបន់អាស៊ី ដែលជាអ្នកទទួលផលនៃគម្រោង EBA របស់សហភាពអឺរ៉ុប ដែលរួមមាន បង់ក្លាដែស ឡាវ និងមីយ៉ាន់ម៉ា ដែលកំពុងតែប្រកួតប្រជែងយកចំណែកទីផ្សារដ៏សំខាន់របស់សហភាពអឺរ៉ុប។ អត្រាប្រើប្រាស់ EBA[11] បានកើនឡើងជាបន្តបន្ទាប់ (ពី 83.1% ដល់ 87.1%)[12] ហើយប្រែប្រួលយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត។ បង់ក្លាដែសគឺជាប្រទេសដែលប្រើគម្រោង EBA ធំជាងគេបំផុត បន្ទាប់មកមានកម្ពុជា។ នៅក្នុងឆ្នាំ 2014 ប្រទេសទទួលផលទាំងពីរនេះរួមគ្នាតំណាងឱ្យប្រមាណ 85.4% នៃការនាំចេញទាំងអស់ ដោយប្រើប្រាស់ប្រព័ន្ធអនុគ្រោះ EBA។[13]

## *តើការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប (Brexit) អាចមានន័យដូចម្តេចសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជា?*

គេមិនច្បាស់ថាតើការចូលទីផ្សារចក្រភពអង់គ្លេស របស់កម្ពុជាដោយប្រព័ន្ធអនុគ្រោះ នឹងនៅតែមាន បន្ទាប់ពីអង់គ្លេសចាកចេញពីសហភាពអឺរ៉ុបឬយ៉ាងណា។ អាចមានលទ្ធភាពមួយចំនួនដូចខាងក្រោម៖

- ចក្រភពអង់គ្លេសនៅតែរក្សាកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះបច្ចុប្បន្ន (គ្មានពន្ធនាំចូល គ្មានកូតា) សម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចបំផុតទាំងអស់ ឬ
- ចក្រភពអង់គ្លេសងាកមករកវិធានរបស់ WTO ដែលនៅក្រោមវិធាននេះ ប្រទេសដែលអង់គ្លេសមិនមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាមួយ ដូចជាកម្ពុជា នឹងលែងទទួលបានការចូលទីផ្សាររបស់ប្រទេសនេះដោយអនុគ្រោះជាស្វ័យប្រវត្តិទៀតហើយ។

ប្រសិនបើចក្រភពអង់គ្លេសងាកមករកវិធាន WTO អ្នកតាក់តែងគោលនយោបាយរបស់កម្ពុជា អាចស្វែងរក FTA ដើម្បីរក្សាភាពអនុគ្រោះបន្តទៅទៀត។

## *ការធ្លាក់ចុះនៃរូបិយប័ណ្ណផោនរបស់អង់គ្លេស ធៀបនឹងដុល្លារអាមេរិក*

ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ រូបិយប័ណ្ណអង់គ្លេសបានធ្លាក់ចុះយ៉ាងខ្លាំង ធៀបនឹងដុល្លារអាមេរិក ការធ្លាក់ចុះនេះទំនងជាមិនមានលក្ខណៈបណ្តោះអាសន្ននោះទេ។ យោងតាម IMF[14] រូបិយប័ណ្ណផោន បានធ្លាក់ចុះជាបន្តបន្ទាប់រយៈពេល 24 ខែ គិតត្រឹមខែកញ្ញា ឆ្នាំ 2016។ តម្លៃផោនគឺប្រមាណ 20 ភាគរយ ទាបជាង

[10] បន្ទាប់ពីមានសេចក្តីសម្រេចដោយសន្និសីទរបស់អង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីយកចេញទស្សនៈអវិជ្ជមានរបស់ខ្លួនចេញពីមីយ៉ាន់ម៉ា កាលពីថ្ងៃទី 12 ខែមិថុនា ឆ្នាំ 2012 សហភាពអឺរ៉ុប បានផ្តល់ប្រព័ន្ធអនុគ្រោះ GSP ជាថ្មីដល់ប្រទេសនេះ កាលពីថ្ងៃទី 19 ខែកក្កដា ឆ្នាំ 2013 ដោយអនុវត្តប្រតិសកម្មចាប់ពីថ្ងៃទី 13 ខែមិថុនា ឆ្នាំ 2012។ ប្រព័ន្ធអនុគ្រោះ GSP ត្រូវបានដកចេញពីមីយ៉ាន់ម៉ា ក្នុងឆ្នាំ 1997 ដោយសារតែមានការរំលោភយ៉ាងធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធទៅលើគោលការណ៍នៃអនុសញ្ញារបស់ ILO ស្តីពីពលកម្មដោយបង្ខំ។

[11] អត្រានៃការប្រើរបបអនុគ្រោះដែលបានផ្តល់ជូន ត្រូវបានគណនាជាចំណែកនៃការនាំចូលដែលអាចទទួលបានរបបនេះ (អំណះអំណាងពី Fabien CANDAU & Sébastien JEAN, No 2005 – 19 ធ្នូ).

[12] អត្រានេះ យោងទៅលើឆ្នាំ 2014 (អត្រាឆ្នាំ 2015 មិនទាន់មាន)

[13] របាយការណ៍គណៈកម្មការអឺរ៉ុប ជូនសភាអឺរ៉ុប និងក្រុមប្រឹក្សា (ចុះថ្ងៃទី 28 ខែមករា ឆ្នាំ2016) ស្តីពីគម្រោងអនុគ្រោះទូទៅ (GSP) សម្រាប់ឆ្នាំ 2014-2015។

[14] កាលប្បវត្តិអត្រាប្តូរប្រាក់របស់ IMF តាមខែ។ មានអនឡាញនៅ៖ http://www.imf.org/external/np/fin/data/param_rms_mth.aspx

នៅក្នុងត្រីមាសទីបីនៃឆ្នាំ 2016 បើប្រៀបធៀប នឹងត្រីមាសដូចគ្នាឆ្នាំ 2015។

ការធ្លាក់ចុះយ៉ាងខ្លាំងនៃរូបិយប័ណ្ណផោន មានន័យថាផលិតផលនាំចូលមានតម្លៃកាន់តែថ្លៃសម្រាប់អតិថិជនអង់គ្លេស។ នេះរួមមានទំនិញដែលនាំចូលពីកម្ពុជា។ កម្ពុជាគឺជាសេដ្ឋកិច្ចដែលប្រើប្រាក់ដុល្លារយ៉ាងខ្លាំងដោយប្រាក់ឈ្នួលអប្បរមា និងការចំណាយផ្សេងទៀតត្រូវបានគ្របដណ្តប់ដោយដុល្លារអាមេរិក។[15] ទោះបីជាអង់គ្លេសមិនទាន់ដកខ្លួនចេញពីសហភាពអឺរ៉ុបក្តីការធ្លាក់ចុះនៃអត្រាប្តូរប្រាក់របស់ខ្លួន មានន័យថាបរិយាកាសពាណិជ្ជកម្មកំពុងតែមានការលំបាកកាន់តែខ្លាំង សម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។ ប្រសិនបើការធ្លាក់ចុះនេះមានរយៈពេលយូរ ការលំបាកនេះនឹងនៅតែមាន។

**រូបទី 3: អត្រាប្តូរប្រាក់របស់សេដ្ឋកិច្ចមួយចំនួនធៀបនឹងដុល្លារអាមេរិក (ការផ្លាស់ប្តូរជាភាគរយ ចាប់តាំងពីខែមករា ឆ្នាំ 2014)**




ប្រភព៖ IMF និងធនាគារកណ្តាលនៃបង់ក្លាដែស

រូបិយប័ណ្ណរបស់ប្រទេសនាំចេញសម្លៀកបំពាក់ និងស្បែកជើងខ្លះ ក៏បានធ្លាក់ចុះផងដែរធៀបនឹងដុល្លារអាមេរិក រួមទាំងរូបិយប័ណ្ណចិន យ័ន រូបិយប័ណ្ណវៀតណាម ដុង និងរូបិយប័ណ្ណបង់ក្លាដែស តាកា។ ដូច្នេះ ផលិតផលនាំចេញរបស់ប្រទេសទាំងនេះមានលក្ខណៈប្រកួតប្រជែងជាមួយផលិតផលនាំចេញរបស់កម្ពុជា។ រូបិយប័ណ្ណយ័នរបស់ចិន បានធ្លាក់ចុះចំនួន 6.4 ភាគរយធៀបនឹងដុល្លារអាមេរិក ពីត្រីមាសទីបីឆ្នាំ 2015 និងត្រីមាសទីបីឆ្នាំ 2016 រីឯរូបិយប័ណ្ណដុងវៀតណាមវិញ បានធ្លាក់ចុះប្រមាណ 1.2 ភាគរយ ក្នុងរយៈពេលដូចគ្នា។ រូបិយប័ណ្ណ តាកា បង់ក្លាដែស បានធ្លាក់ចុះប្រមាណជិត 1 ភាគរយ។[16] ការធ្លាក់ចុះនៃរូបិយប័ណ្ណរបស់ប្រទេសផលិតសម្លៀកបំពាក់ទាំងនេះ មានន័យថា ការនាំចេញរបស់ពួកគេ នឹងមិនប៉ះពាល់អវិជ្ជមានដោយការធ្លាក់ចុះរូបិយប័ណ្ណរបស់អង់គ្លេសក្នុងកម្រិតដូចគ្នានឹងកម្ពុជាឡើយ។ ការនាំចូលរបស់អង់គ្លេស ទំនងជានឹងធ្លាក់ចុះជារួម (ដោយសារតែការធ្លាក់ចុះពិតនៃរូបិយប័ណ្ណផោន GBP) រីឯសមាសភាពនៃផលិតផលនាំចូលដែលនៅសល់ អាចមានការប្រែប្រួលក្នុងកម្រិតមួយដែលឆ្ងាយពីផលិតផលរបស់កម្ពុជា។

Brexit អាចបង្កហានិភ័យរយៈពេលខ្លីចំពោះផលិតផលនាំចេញសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជា តាមរយៈផលប៉ះពាល់មក លើអត្រាប្តូរប្រាក់របស់អង់គ្លេស ខណៈពេលដែលហានិភ័យរយៈពេលវែង គឺបង្កឡើងដោយសក្តានុពលនៃការបាត់បង់ការចូលទីផ្សារចក្រភពអង់គ្លេសដោយគ្មានពន្ធនាំចូល។

## ខ. ការដំឡើងស្ថានភាពសេដ្ឋកិច្ចរបស់កម្ពុជា

កាលពីខែកក្កដាឆ្នាំ 2016 ធនាគារពិភពលោកបានពិនិត្យឡើងវិញលើស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសជាសមាជិកចំនួន 189 ប្រទេសនិងសេដ្ឋកិច្ចចំនួន 28 ផ្សេងទៀតដែលមានប្រជាជនច្រើនជាង 30,000 នាក់។[17] ធនាគារពិភពលោកបានបែងចែកសេដ្ឋកិច្ចជាបួនក្រុមប្រាក់ចំណូល យោងតាមប្រាក់ចំណូលជាតិសរុបឆ្នាំ 2015 (GNI) ក្នុងមនុស្សម្នាក់ ដូចខាងក្រោម៖

[15] ជាសញ្ញាមួយនៃទំហំនៃការប្រើប្រាក់ដុល្លារនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ គេគួរកត់សម្គាល់ថាប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស តំណាងឱ្យប្រមាណ 83 ភាគរយនៃប្រាក់ទូទៅរបស់ប្រទេស (យោងតាមមូលដ្ឋានទិន្នន័យរូបិយវត្ថុនៃធនាគារជាតិនៃកម្ពុជា)។

[16] កាលប្បវត្តិអត្រាប្តូរប្រាក់របស់ IMF តាមខែ។ មានអនឡាញនៅ៖ http://www.imf.org/external/np/fin/data/param_rms_mth.aspx និងរតនាគារនៃអត្រាប្តូរប្រាក់ប្រតិបត្តិការអង្គការសហប្រជាជាតិ មានអនឡាញនៅ៖ https://treasury.un.org/operationalrates/OperationalRates.php#V

[17] http://www.worldbank.org// (ការគណនាប្រើវិធីសាស្ត្រ Atlas)

1 - ប្រាក់ចំណូលទាប គឺ 1,025 ដុល្លារ ឬ តិចជាងនេះ

2 - ប្រាក់ចំណូលមធ្យមកម្រិតទាប គឺពី 1,026–4,035 ដុល្លារ

3 - ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ គឺ ពី 4,036–12,475 ដុល្លារ

4 - នឹង ប្រាក់ចំណូលខ្ពស់ គឺ 12,476 ដុល្លារ ឡើងទៅ។

ប្រាក់ចំណូលជាតិសរុបរបស់កម្ពុជាក្នុងមនុស្សម្នាក់ បានឡើងដល់ 1,070 ដុល្លារអាមេរិកក្នុងឆ្នាំ 2015 កើនឡើងពី 1,020 ដុល្លារអាមេរិកក្នុងឆ្នាំ 2014។[18] ដូច្នេះកម្ពុជាឆ្លើយតបតាមចំណាត់ថ្នាក់ថ្មី និងរំកិលពីស្ថានភាពប្រទេសដែលមានប្រាក់ចំណូលទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ កម្ពុជាមានស្ថានភាពថ្មីនេះដូចគ្នានឹងសេដ្ឋកិច្ច 52 ផ្សេងទៀតរួមទាំងវៀតណាម ឥណ្ឌូនេស៊ី និងហ្វីលីពីន។ កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសប្រាំមួយគត់ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ជាថ្មីដោយធនាគារពិភពលោកនៅក្នុងឆ្នាំ 2016[19] ទោះបីជាប្រទេសនៅតែត្រូវបានចាត់ថ្នាក់ថា ជាប្រទេសដែលមានការអភិវឌ្ឍតិចបំផុតដោយអង្គការសហប្រជាជាតិសម្រាប់ពេលបច្ចុប្បន្នក្តី។[20]

ខណៈពេលដែលការឡើងឋានៈនេះ ឆ្លុះបញ្ចាំងពីភាពជឿនលឿននៃសេដ្ឋកិច្ចកម្ពុជា ប្រទេសនេះក៏នៅតែអាចនឹងធ្លាក់ចុះវិញបានដែរ។ ស្ថានភាពប្រទេសដែលមានការអភិវឌ្ឍតិចបំផុតរបស់កម្ពុជាមានន័យថា ប្រទេសនេះមានសិទ្ធិទទួលបានគម្រោង EBA របស់សហភាពអឺរ៉ុប ដែលតាមរយៈគម្រោងនេះកម្ពុជាអាចចូលទីផ្សារនៃប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំង 28 ប្រទេសដោយគ្មានពន្ធនាំចូល និងគ្មានកូតា។ កិច្ចព្រមព្រៀងប្រព័ន្ធអនុគ្រោះ អាចត្រូវបានដកចេញ នៅពេលកម្ពុជាលែងជាប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជា។

តើមានអ្វីកើតឡើងនៅពេលប្រទេសមួយលែងត្រូវបានចាត់ទុកជាប្រទេសដែលមាន "ការអភិវឌ្ឍតិចបំផុត" ដោយអង្គការសហប្រជាជាតិ? យោងតាមគណៈកម្មការអឺរ៉ុប *"នៅពេលប្រទេសរំកិលឡើងលើជណ្តើរអភិវឌ្ឍន៍ដោយជោគជ័យ ការខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានទទួលស្គាល់ ហើយពួកគេលែងត្រូវបានអង្គការសហប្រជាជាតិចាត់ទុកថា "អភិវឌ្ឍតិចតួចបំផុត" ទៀតហើយ។ ដូច្នេះ គេលែងត្រូវការប្រព័ន្ធអនុគ្រោះ EBA ទៀតហើយ។ ការវិវឌ្ឍដោយរលូនចូលទៅក្នុងការផ្លាស់ប្តូរស្ថានភាពនេះត្រូវបានធានាដោយរយៈពេលអន្តរកាលប្រកបដោយភាពសប្បុរសធម៌ចំនួនបីឆ្នាំ ដែលនៅក្នុងពេលនេះ ប្រព័ន្ធអនុគ្រោះ EBA នឹងបន្តអនុវត្តតទៅទៀត។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយបញ្ហាលំហូរពាណិជ្ជកម្មដែលអាចមាន និងជាការឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់សហភាពអឺរ៉ុបចំពោះវឌ្ឍនភាពជាបន្តរបស់ប្រទេសកំពុងអភិវឌ្ឍន៍"។*[21] *ចំណាត់ថ្នាក់សេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិមានលក្ខណៈពហុផ្នែក ដោយពឹងផ្អែកលើកត្តាផ្សេងទៀតក្រៅពីផសស ក្នុងមនុស្សម្នាក់ ប៉ុន្តែការដំឡើងស្ថានភាពរបស់កម្ពុជាដោយធនាគារពិភពលោក អាចជាសញ្ញាមួយដែលថា ការដំឡើងដោយអង្គការសហប្រជាជាតិ អាចធ្វើតាមទិន្នានាការនេះដែរ។*

ដោយសារតែរយៈពេលអន្តរកាលនេះ ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប ទំនងជាមិនប៉ះពាល់រយៈពេលខ្លីទេ ប៉ុន្តែកម្ពុជាត្រូវតែរៀបចំខ្លួនឱ្យបានល្អ ដើម្បីគ្រប់គ្រងផលប៉ះពាល់រយៈពេលមធ្យមចំពោះការផ្លាស់ប្តូរស្ថានភាពនៃការអភិវឌ្ឍ។

## គ. ការចូលទីផ្សារសហរដ្ឋអាមេរិកសម្រាប់ទំនិញធ្វើដំណើរ ផ្អែកលើប្រព័ន្ធអនុគ្រោះ

ថ្មីៗនេះ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានធ្វើវិសោធនកម្មទៅលើប្រព័ន្ធអនុគ្រោះទូទៅរបស់ខ្លួន (GSP) ហើយបានប្រកាសថាប្រទេសនេះបានផ្តល់ដល់កម្ពុជា នូវការចូលទីផ្សាររបស់ខ្លួនសម្រាប់ទំនិញធ្វើដំណើរដោយគ្មានពន្ធនាំចូល ដោយចូលជាធរមានចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2016។[22] សហរដ្ឋអាមេរិកបាន ផ្តល់

---

[18] ធនាគារពិភពលោក GNI ក្នុងមនុស្សម្នាក់ វិធីសាស្ត្រ Atlas (រូបិយប័ណ្ណ US$)

[19] ចំណាត់ថ្នាក់វិភាគរបស់ធនាគារពិភពលោក (GNI ក្នុងមនុស្សម្នាក់ គិតជា US$, វិធីសាស្ត្រ Atlas)

[20] UN 2016, *ស្ថានភាពសេដ្ឋកិច្ចពិភពលោក និងទស្សនវិស័យ ២០១៦,* p.163

[21] កំណត់សម្គាល់គណៈកម្មការអឺរ៉ុប 2014, "គ្រប់យ៉ាងលើកលែងតែអាវុធ (EBA) – តើអ្នកណាខ្លះទទួលបានអត្ថប្រយោជន៍នេះ?" (http://trade.ec.europa.eu/doclib/docs/2014/october/tradoc_152839.pdf)

[22] សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី 6 ខែកក្កដា ឆ្នាំ 2016 ស្តីពី

ស្ថានភាព GSP សម្រាប់ទំនិញធ្វើដំណើរដល់តែ "ប្រទេសដែលមានការអភិវឌ្ឍតិចបំផុត" មួយចំនួនតូច និង សម្រាប់កំណើននៃទ្វីបអាហ្វ្រិក និង ប្រទេសដែលមានកាលានុវត្តភាព (African Growth and Opportunity Act countries) តែប៉ុណ្ណោះ។

**តារាងទី 4: ការនាំចេញទំនិញធ្វើដំណើររបស់កម្ពុជា ទៅកាន់ទីផ្សារធំៗ (គិតជាលានដុល្លារអាមេរិក)***

| | 2014 | 2015 |
|---|---|---|
| ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក | US$ 21.0 | US$ 50.4 |
| ពន្ធនាំចូលប្រហាក់ប្រហែលដែលបង់ (MFN) | US$ 3.4 | US$ 8.5 |
| អត្រាពន្ធជាមធ្យមដែលបានបង់ | 16.5% | 16.5% |
| តម្លៃចន្លោះនៃអត្រាពន្ធ | 3.4% to 20% | 3.4% to 20% |
| ទៅកាន់ទីផ្សារអឺរ៉ុប ២៨ ប្រទេស | US$ 8.1 | US$ 27.5 |
| គ្មានពន្ធនាំចូល | 0.0% | 0.0% |
| **នាំចេញសរុប** | **US$ 57.3** | **US$ 91.6** |
| %នៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក | 36.6% | 55.0% |
| % នៃការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប | 14.1% | 30.0% |
| % នៃការនាំចេញសរុបទៅកាន់ទីផ្សារអឺរ៉ុប និងសហរដ្ឋអាមេរិក | 50.8% | 85.0% |
| % នៃទីផ្សារនាំចេញរបស់ទំនិញធ្វើដំណើរពិភពលោក | 0.09% | 0.15% |

ប្រភព៖ គណៈកម្មការពាណិជ្ជកម្មអន្តរជាតិសហរដ្ឋអាមេរិក, EuroStat និង UNCTAD

* កំណត់សម្គាល់៖ សូមមើលពន្ធនាំចូលសុខដុមនីយកម្ម 4 ខ្ទង់ (4202) ប្រភេទទំនិញធ្វើដំណើរ ដែលរួមមាន (ទំនិញធ្វើដំណើរ ប្រអប់ដាក់គ្រឿងសម្អាង កាបូបដាក់កែវយឹត និងម៉ាស៊ីនថត កាបូបដៃ កាបូបលុយ កាបូបដាក់ស្លាបព្រាកាំបិត និងកាបូបឬប្រអប់សម្រាប់ដាក់សម្ភារៈផ្សេងៗស្រដៀងគ្នា)

ការលុបចោលពន្ធគយរបស់សហរដ្ឋអាមេរិក សម្រាប់ផលិតផលធ្វើដំណើរដែលផលិតនៅកម្ពុជា ដូចជា វ៉ាលីដាក់ខោអាវ កាបូបដៃ កាបូបលុយ ប្រអប់ដាក់គ្រឿងសំអាង និងផលិតផលស្រដៀងគ្នាផ្សេងទៀត ត្រូវបានគេជឿជាទូទៅថា គឺជាគោលនយោបាយពាណិជ្ជកម្មដ៏សំខាន់មួយ ដើម្បីជួយលើកស្ទួយឧស្សាហកម្មផលិតទំនិញធ្វើដំណើររបស់កម្ពុជា។ កន្លងមក ទំនិញធ្វើដំណើររបស់កម្ពុជា បានជួបប្រទះអត្រាពន្ធនាំចូលរបស់សហរដ្ឋអាមេរិក ពី 3.4 ទៅ 20 ភាគរយ ហើយឥឡូវនេះ អាចចូលទីផ្សារសហរដ្ឋអាមេរិកដោយគ្មានពន្ធនាំចូល។ បច្ចុប្បន្ននេះ សហរដ្ឋអាមេរិកគឺជាគោលដៅនាំចេញធំបំផុត សម្រាប់ទំនិញធ្វើដំណើររបស់កម្ពុជា។

ឧស្សាហកម្មទំនិញធ្វើដំណើររបស់កម្ពុជា នៅតែស្ថិតក្នុងដំណាក់កាលក្មេងខ្ចីនៅឡើយ។ កាលពីឆ្នាំកន្លងទៅ កម្ពុជាបាននាំចេញទំនិញធ្វើដំណើរ ដែលមានតម្លៃទឹកប្រាក់ចំនួន 91.6 លានដុល្លារអាមេរិក ដែលតំណាងឱ្យប្រមាណតែ 1.3 ភាគរយនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងសរុបរបស់ប្រទេសនេះ។ នៅក្នុងឆ្នាំ 2015 សហរដ្ឋអាមេរិកតំណាងឱ្យប្រមាណ 55 ភាគរយនៃការនាំចេញទំនិញធ្វើដំណើរការរបស់កម្ពុជា។ ទោះបីជាយ៉ាងណាក្តី ចរភាពកំណើនរបស់ឧស្សាហកម្មនាំចេញទំនិញធ្វើដំណើររបស់កម្ពុជា ហាក់ដូចជាមានសន្ទុះខ្លាំង ដោយក្នុងនោះការនាំចេញកើនឡើងចំនួន 60 ភាគរយ ក្នុងឆ្នាំ 2015 លើកម្រិតនាំចេញឆ្នាំ 2014។ ក្រសួងពាណិជ្ជកម្មរបស់កម្ពុជា និងសមាគមរោងចក្រកាត់ដេរនៃកម្ពុជា (GMAC) មានសុទិដ្ឋិនិយមថា ប្រព័ន្ធអនុគ្រោះនៃអត្រាពន្ធនាំចូលសូន្យដែលផ្តល់ដោយសហរដ្ឋអាមេរិក ជួយជំរុញកំណើនរបស់វិស័យនេះ ព្រមទាំងទាក់ទាញការវិនិយោគកាន់តែច្រើនថែមទៀតមកក្នុងវិស័យនេះក្នុងពេលអនាគត ដែលនឹងបង្កើតកាលានុវត្តភាពការងារកាន់តែច្រើនថែមទៀតសម្រាប់ប្រជាជនកម្ពុជា។[23] វិស័យទំនិញធ្វើដំណើរ និងកាបូបយួរដៃ គឺជាឧស្សាហកម្មដែលមានតម្លៃខ្ពស់គួរសម បើប្រៀបធៀបទៅនឹងផ្នែកនៃឧស្សាហកម្មដ៏ទៃទៀត ដូចជា ប្រតិបត្តិការកាត់ដេរសម្លៀកបំពាក់។ ដូច្នេះ វិស័យនេះត្រូវការជំនាញកាន់តែខ្ពស់ថែមទៀត ពីកម្លាំងការងារ ក៏ដូចជាការវិនិយោគនៅក្នុងគ្រឿងចក្រ និងដំណើរការអាជីវកម្ម ដើម្បីប្រកួតប្រជែងលើគុណភាព។

ᶜការចូលទីផ្សារដោយគ្មានពន្ធនាំចូលសម្រាប់ទំនិញធ្វើដំណើរដែលផលិតនៅក្នុងប្រទេសកម្ពុជា ᶜ https://kh.usembassy.gov/duty-free-access-travel-goods-made-cambodia/

[23] យោងតាមអត្ថបទនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ និងដំណឹងថ្មីៗ (Fresh News) (ចុះថ្ងៃទី 7 ខែកក្កដា ឆ្នាំ 2016)

តាមប្រសាសន៍រាយការណ៍របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)

ការចូលទីផ្សារសហរដ្ឋអាមេរិកដោយប្រព័ន្ធអនុគ្រោះសម្រាប់ទំនិញធ្វើដំណើររបស់កម្ពុជា នឹងជួយពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ប្រៀបធៀបនឹងប្រទេសផ្សេងទៀតដែលផលិតទំនិញនេះដែរ។ មានឱកាសយ៉ាងច្រើនសម្រាប់កំណើន - ការនាំចេញទំនិញធ្វើដំណើររបស់កម្ពុជា នៃទីផ្សារនាំចេញទំនិញធ្វើដំណើរក្នុងសកលលោកសរុប មានតែ 0.15 ភាគរយប៉ុណ្ណោះ ក្នុងឆ្នាំ 2015។ សហរដ្ឋអាមេរិក គឺជាប្រទេសទិញទំនិញធ្វើដំណើរធំជាងគេ ក្នុងពិភពលោក។ ក្នុងឆ្នាំ 2015 ប្រទេសនេះបាននាំចូលទំនិញធ្វើដំណើរដែលមានតម្លៃប្រមាណ 12 ពាន់លានដុល្លារអាមេរិក ដែលតំណាងឱ្យ 20.2 ភាគរយ នៃការនាំចូលទំនិញធ្វើដំណើរក្នុងសកលលោក កើនឡើងពី 18.7 ភាគរយក្នុងឆ្នាំ 2014។ ការបើកចូលទីផ្សារដោយគ្មានពន្ធនាំចូលសម្រាប់ទីផ្សារនេះ ផ្តល់កាលានុវត្តភាពដ៏ធំមួយសម្រាប់កម្ពុជា។

**តារាងទី 5៖ ប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៥ លើគេ ដែលនាំចេញទំនិញធ្វើដំណើរទៅក្នុងទីផ្សារសកលលោក (ជា % នៃទីផ្សារទំនិញធ្វើដំណើរក្នុងសកលលោក)**

| | 2000 | 2005 | 2010 | 2015 |
|---|---|---|---|---|
| សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ | 68.5% | 60.3% | 65.5% | 65.6% |
| ចិន | 23.5% | 31.1% | 44.4% | 46.1% |
| ហុងកុង ចិន | 28.7% | 20.3% | 13.2% | 7.7% |
| វៀតណាម | 1.0% | 1.3% | 1.9% | 4.0% |
| ឥណ្ឌា | 2.0% | 2.2% | 1.8% | 2.0% |
| សិង្ហបុរី | 0.3% | 0.7% | 0.8% | 1.3% |
| ផ្សេងទៀត | 31.5% | 39.7% | 34.5% | 34.4% |
| សរុប | 100% | 100% | 100% | 100% |

ប្រភព៖ UNCTAD (ដកស្រង់ចេញនៅថ្ងៃ 1 វិច្ឆិកា 2016)

ចិនគឺជាប្រទេសនាំចេញទំនិញធ្វើដំណើរធំជាងគេក្នុងពិភពលោក ដោយនៅក្នុងឆ្នាំ 2015 ការនាំចេញទំនិញធ្វើដំណើរ របស់ ប្រទេសនេះ ស្មើនឹង 65.6 ភាគរយ នៃទីផ្សារទំនិញធ្វើដំណើរ ក្នុងសកលលោក។ វៀតណាម និងសិង្ហបុរី បាននិងកំពុងទទួល បានចំណែកទីផ្សារសកលកាន់តែខ្ពស់ សម្រាប់ទំនិញធ្វើដំណើរក្នុង រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។

កម្ពុជាអាចមានលទ្ធភាពចាប់យកចំណែកទីផ្សារនេះខ្លះក្នុងពេលអនាគត។

## 3. សន្និដ្ឋាន

វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជា ទំនងជានៅតែជាវិស័យនាំចេញធំជាងគេបំផុតនៃសេដ្ឋកិច្ចរបស់ខ្លួន យ៉ាងហោចណាស់ក្នុងរយៈពេលមធ្យម។ ការវិវឌ្ឍថ្មីៗនៅក្នុងគោលនយោបាយពាណិជ្ជកម្ម ត្រូវគេរំពឹងថានឹងបង្កហានិភ័យផង និងកាលានុវត្តភាពផង សម្រាប់វិស័យនាំចេញរបស់ប្រទេសនេះ។

Brexit: ចក្រភពអង់គ្លេសគឺជាទីផ្សារដ៏សំខាន់មួយសម្រាប់កម្ពុជា ជាប្រទេសនាំចូលធំបំផុតនៃផលិតផលសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាក្នុងចំណោមរដ្ឋជាសមាជិក 28 នៃសហភាពអឺរ៉ុប។ ការចាកចេញរបស់អង់គ្លេស កំពុងតែបង្កផលប៉ះពាល់មកលើកម្ពុជារួចទៅហើយ តាមរយៈផលប៉ះពាល់របស់វាមកលើតម្លៃរបស់ផោន។ ផលប៉ះពាល់កាន់តែខ្លាំងថែមទៀតអាច នឹងកើតឡើងរយៈពេលវែង ប្រសិនបើការទទួលបានពាណិជ្ជកម្មដែលមានភាពអនុគ្រោះត្រូវបានបាត់បង់។ ប្រសិនបើគ្មានការចូលទីផ្សារចក្រភពអង់គ្លេសដោយមានការអនុគ្រោះទេនោះ កម្ពុជានឹងប្រឈមមុខនឹងសម្ពាធប្រកួតប្រជែងកាន់តែខ្លាំង ដោយអាចមានជាផលវិបាកអវិជ្ជមានចំពោះការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់ខ្លួន ព្រមទាំងការងារនិងមុខរបរនៅក្នុងវិស័យនេះ។

**ការដំឡើងស្ថានភាពសេដ្ឋកិច្ច៖** ធនាគារពិភពលោកបានដំឡើងកម្ពុជាពីប្រទេសដែលមានការអភិវឌ្ឍតិចបំផុត (LDC)។ ដែលនេះអាចជាសញ្ញាមួយសម្រាប់ការដំឡើងដូចគ្នា ដោយអង្គការសហប្រជាជាតិ។ ប្រសិនបើការដំឡើងនេះកើតឡើងមែន កម្ពុជាអាចបាត់បង់ការទទួលបានប្រព័ន្ធ EBA របស់សហភាពអឺរ៉ុបសម្រាប់ប្រទេសដែលមានការអភិវឌ្ឍតិចបំផុត។ បញ្ហានេះនឹងមិនកើតឡើងទេ យ៉ាងហោចណាស់សម្រាប់រយៈពេលបីឆ្នាំទៀត ដោយហេតុថា មានពេលវេលាផ្តល់ដើម្បីធ្វើការរៀបចំអន្តរកាល។ វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងកម្ពុជា មានពេលខ្លះដើម្បីរៀបចំសម្រាប់បរិយាកាសមួយ ដែលគុណប្រយោជន៍ប្រកួត

ប្រជែង អាចត្រូវបានកាត់បន្ថយដោយសារការបាត់បង់ស្ថានភាព EBA ប៉ុន្តែ វិស័យនេះត្រូវតែសម្របទៅនឹងស្ថានភាពជាក់ស្តែងនេះ ក្នុងរយៈពេលមធ្យម។

**ប្រព័ន្ធអនុគ្រោះទូទៅ (GSP) ពីសហរដ្ឋអាមេរិកសម្រាប់ទំនិញធ្វើដំណើរ៖** ទីផ្សារសហរដ្ឋអាមេរិក កំពុងតែបាត់បង់នូវសារៈសំខាន់របស់ខ្លួនជាគោលដៅមួយសម្រាប់ការនាំចេញសំលៀក បំពាក់និងស្បែកជើងកម្ពុជា។ ទោះបីជាយ៉ាងណាក្តី ការបើកឱ្យចូលទីផ្សារសហរដ្ឋអាមេរិកដោយគ្មានពន្ធនាំចូល សម្រាប់ទំនិញធ្វើដំណើរពីកម្ពុជា គឺជាកាលានុវត្តភាពដ៏សំខាន់មួយសម្រាប់វិស័យនេះ។ ភាគីពាក់ព័ន្ធនៃឧស្សាហកម្មកម្ពុជា រំពឹងថានឹងឃើញកំណើននៃការវិនិយោគ និងការនាំចេញទំនិញធ្វើដំណើរក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ រដ្ឋាភិបាលកម្ពុជា បាននឹងកំពុងបង្ហាញ និងផ្សព្វផ្សាយគោលនយោបាយពាណិជ្ជកម្មថ្មីរបស់សហរដ្ឋអាមេរិក ដល់វិនិយោគិនដែលមានសក្តានុពលនានា។ មានកាលានុវត្តភាពយ៉ាងច្រើន។

គេគួរកត់សម្គាល់ថា ភាពអនុគ្រោះទូទៅ GSP អាចដកចេញវិញបាន។ ការិយាល័យតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ត្រូវបានគេដកស្រង់សំដីនាពេលថ្មីៗនេះថា "អភ័យឯកសិទ្ធិ GSP របស់ប្រទេសអាចត្រូវបានកម្រិតវិសាលភាព ឬដកចេញ ប្រសិនបើរកឃើញថាមានការរំលោភលើ*និយាមដែលគេទទួលស្គាល់ជាអន្តរជាតិសម្រាប់សិទ្ធិកម្មករ*។[24] ដូច្នេះ ការអនុលោមតាម និយាមការងារអន្តរជាតិ គួរតែជាសមាសធាតុដ៏សំខាន់មួយនៃយុទ្ធសាស្ត្រឧស្សាហកម្មរបស់កម្ពុជា។

**ការវិវឌ្ឍផ្សេងទៀត៖** ការវិវឌ្ឍគោលនយោបាយពាណិជ្ជកម្មផ្សេងទៀតអាចនឹងកើតឡើង ដែលអាចប៉ះពាល់ដល់កម្ពុជា រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប និងវៀតណាម។ អត្ថបទនៃកិច្ចព្រមព្រៀងត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2016។ កិច្ចព្រមព្រៀងនេះនឹងត្រូវបានបង្ហាញដោយសហភាពអឺរ៉ុបដល់គណៈរដ្ឋមន្ត្រីសហភាពអឺរ៉ុប ដើម្បីអនុម័ត និងផ្តល់សច្ចាប័នដោយសភាពអឺរ៉ុប។ កិច្ចព្រមព្រៀងនេះនឹងលុបបំបាត់ពន្ធនាំចូលជិត 99 ភាគរយ លើពាណិជ្ជកម្មរវាងវៀតណាម និងសហភាពអឺរ៉ុប។[25] បញ្ហានេះអាចធ្វើឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជាសម្រាប់ផលិតផលសម្លៀកបំពាក់ និងស្បែកជើង។ ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ប្រសិនបើត្រូវបានអនុម័តមែននោះ ក៏អាចមានផលប៉ះពាល់យ៉ាងខ្លាំងមកលើកម្ពុជា និងប្រទេសផ្សេងទៀតក្នុងតំបន់ផងដែរ។ TPP នឹងបង្កើតជាប្លុកពាណិជ្ជកម្មមួយ ដែលនឹងរួមបញ្ចូលវៀតណាម និងម៉ាឡេស៊ី ប៉ុន្តែមិនមានកម្ពុជាទេ។ ការរំពឹងនូវការអនុម័ត TPP មិនមានភាពច្បាស់លាស់ទេ។

[24] ដកស្រង់ចេញពីកាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី 7 ខែកក្កដា ឆ្នាំ 2016 ដោយយោងព័ត៌មានពីការិយាល័យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក (USTR)

[25] សហភាពអឺរ៉ុប និងវៀតណាម រៀបចំបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មដ៏ធំ, ក្រុងប្រ៊ុសែល ថ្ងៃ 2 ធ្នូ 2015 មាននៅ (http://trade.ec.europa.eu/doclib/press/index.cfm?id=1409)

## ផ្នែកទី II - ស្ថិតិបច្ចុប្បន្នភាព

ផ្នែកទី II នៃព្រឹត្តិបត្រព័ត៌មាននេះ ផ្តល់នូវព័ត៌មានបច្ចុប្បន្នភាពអំពីការវិវឌ្ឍថ្មីៗនៅក្នុងវិស័យនេះ។

### 1. ការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើង

យោងតាមអគ្គនាយកដ្ឋានគយ និងរដ្ឋាករ របស់កម្ពុជា (GDCE) វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា បន្តលូតលាស់ក្នុងអំឡុងពេលឆមាសទីមួយនៃឆ្នាំ 2016 ដោយការ នាំចេញកើនឡើងចំនួន 10.8 ភាគរយ ស្មើនឹង 3.5 ពាន់លានដុល្លារអាមេរិកក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ។ ការនាំចេញសំលៀកបំពាក់និងស្បែកជើង តំណាងឱ្យប្រមាណ 73 ភាគរយនៃការនាំចេញទំនិញសរុបរបស់កម្ពុជា ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ 2016។

ការនាំចេញផលិតផលស្បែកជើង បានកើនឡើងចំនួន 13.4 ភាគរយ ស្មើនឹង 359 លានដុល្លារអាមេរិក ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ 2016 ចំណែកឯការនាំចេញសម្លៀកបំពាក់វិញ បានកើនឡើងចំនួន 10.5 ភាគរយ ស្មើនឹង 3.1 ពាន់លានដុល្លារអាមេរិក ក្នុងអំឡុងពេលដូចគ្នា។

ទីផ្សារអឺរ៉ុប នៅតែជាអ្នកបញ្ជាទិញធំផុតនៃផលិតផលសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា ដែលតំណាងឱ្យប្រមាណ 45 ភាគរយនៃការនាំចេញរបស់កម្ពុជា ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ 2016 រីឯទីផ្សារសហរដ្ឋអាមេរិក តំណាងឱ្យប្រមាណតែ 25 ភាគរយ ប៉ុណ្ណោះ។ 30 ភាគរយដែលនៅសល់ ត្រូវបាន នាំចេញទៅកាន់ទីផ្សារផ្សេងទៀត ជាពិសេស កាណាដា និង ជប៉ុន។

**រូបទី 4: ការនាំចេញផលិតផលសម្លៀកបំពាក់និង ស្បែកជើងរបស់កម្ពុជា ឆ្នាំ 2000–2016 (លានដុល្លារអាមេរិក)**




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

កម្ពុជាស្ថិតក្នុងចំណោមប្រទេសនាំចេញសម្លៀកបំពាក់ និងស្បែកជើងចំនួន 10 ធំជាងគេ ក្នុងចំណោមសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ ចំណែកទីផ្សារនៃផលិតផលសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា បានកើនឡើងពី 0.7 ភាគរយ ក្នុងឆ្នាំ 2005 ដល់ 1.5 ភាគរយ ក្នុងឆ្នាំ 2015។[26]

ចិននៅតែជាប្រទេសនាំចេញផលិតសម្លៀកបំពាក់ និងស្បែកជើងធំបំផុតក្នុងពិភពលោក ដែលតំណាងឱ្យប្រមាណ 37.6 ភាគរយនៃការនាំចេញក្នុងសកលលោក បន្ទាប់មក មានវៀតណាម 5.9 ភាគរយ អ៊ីតាលី 5.2 ភាគរយ និង បង់ក្លាដែស 4.4 ភាគរយ។ វៀតណាម និងបង់ក្លាដែស បានបង្កើនចំណែកទីផ្សាររបស់ខ្លួនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ វៀតណាមបានពង្រីកចំណែកទីផ្សាររបស់ខ្លួនក្នុងសកលលោក ពី 2.1 ភាគរយ ក្នុងឆ្នាំ 2005 ដល់ 5.9 ក្នុងឆ្នាំ 2015 រីឯបង់ក្លាដែស បានបង្កើន ចំណែកទីផ្សារក្នុងសកលលោករបស់ខ្លួនពី 2.0 ភាគរយ ក្នុងឆ្នាំដល់ 4.4 ភាគរយ ក្នុងឆ្នាំ 2015។ កម្ពុជាបានបង្កើនចំណែកទីផ្សាររបស់ខ្លួនក្នុងសកលលោកទ្វេដងក្នុងរយៈពេលដូចគ្នា ពីកម្រិតមូលដ្ឋានទាបជាងប្រទេសទាំងពីរនេះ។

[26] Cambodia's ចំណែកនៃការនាំចេញផលិតផលសំលៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ គឺ 2.0 ភាគរយ ក្នុងឆ្នាំ 2015។

**តារាងទី 6៖ ការនាំចេញផលិតផលសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា ជាចំណែកនៃការនាំចេញសម្លៀក បំពាក់ និងស្បែកជើងក្នុងសកលលោក (ភាគរយ)**

| | 2005 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|
| សេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ | 64.9 | 68.4 | 68.1 | 69.8 | 69.8 | 69.6 | 71.2 |
| 1. ចិន | 25.7 | 35.1 | 35.3 | 37.5 | 37.8 | 37.8 | 37.6 |
| 2. វៀតណាម | 2.1 | 3.3 | 3.6 | 4.0 | 4.3 | 4.8 | 5.9 |
| 3. បង់ក្លាដែស | 2.0 | 3.3 | 3.6 | 3.7 | 3.9 | 3.9 | 4.4 |
| 4. ហុងកុង ចិន | 9.2 | 6.3 | 5.4 | 5.0 | 4.4 | 3.9 | 3.7 |
| 5. ឥណ្ឌា | 2.7 | 2.7 | 3.0 | 2.9 | 3.2 | 3.2 | 3.5 |
| 6. តួគី | 3.3 | 2.8 | 2.6 | 2.7 | 2.7 | 2.7 | 2.6 |
| 7. ឥណ្ឌូនេស៊ី | 1.8 | 2.0 | 2.0 | 2.0 | 1.9 | 1.8 | 1.9 |
| 8. កម្ពុជា | **0.7** | **0.9** | **0.9** | **1.0** | **1.1** | **1.2** | **1.5** |
| 9. ប៉ាគីស្ថាន | 1.0 | 0.9 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| 10. ម៉ិកស៊ិក | 2.1 | 1.0 | 0.9 | 0.9 | 0.9 | 0.8 | 0.8 |
| ផ្សេងទៀត | 35.1 | 31.6 | 31.9 | 30.2 | 30.2 | 30.4 | 28.8 |
| ពិភពលោក | 100 | 100 | 100 | 100 | 100 | 100 | 100 |

ប្រភព UNCTAD

## 2. ការវិនិយោគថ្មី ការបើក និងការបិទរោងចក្រ

**ក – ការវិនិយោគថ្មី៖** ការវិនិយោទុនបរទេសថ្មី បន្តហូរចូលក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងកម្ពុជាក្នុងអំឡុងពេលប្រាំមួយខែដំបូងនៃឆ្នាំ 2016។ គណៈកម្មាធិការវិនិយោគកម្ពុជា (CIB) បានអនុម័តគម្រោងវិនិយោគថ្មីចំនួន 60 គម្រោង ដែលក្នុងនោះមានគម្រោងសម្លៀកបំពាក់ចំនួន 25 និងស្បែកជើង 6 គម្រោង។

ខណៈដែលគម្រោងវិនិយោគទុនជាច្រើន ដែលត្រូវបានអនុម័តនាពេលថ្មីៗនេះស្ថិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង តែតម្លៃនៃគម្រោងទាំងនេះរួមមានប្រមាណតែ 7 ភាគរយនៃតម្លៃ 1,782 លានដុល្លារអាមេរិក នៃការវិនិយោគដែលបានអនុម័តថ្មីទាំងអស់។ ផលធៀបនេះបានធ្លាក់ចុះពី 28 ភាគរយក្នុងឆ្នាំ 2014 និង 10 ភាគរយក្នុងឆ្នាំ 2015 ដែលបង្ហាញថា មានគម្រោងវិនិយោគដែលមានតម្លៃកាន់តែខ្ពស់នៅក្នុងវិស័យផ្សេងទៀតក្រៅពីវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។

ចិននៅតែជាប្រទេសនាំមុខគេដែលវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមការវិនិយោគថ្មីដែលបានអនុវម័ត (គិតជាតម្លៃទឹកប្រាក់) នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនៅក្នុងអំឡុងពល 6 ខែដំបូងនៃឆ្នាំ 2016 វិនិយោគិនមកពីចិនដីគោក តំណាងឱ្យប្រមាណ 38 ភាគរយ ចក្រភពអង់គ្លេសមានប្រមាណ 13 ភាគរយ តៃវ៉ាន់មាន 8 ភាគរយ ហុងកុង មាន 4 ភាគរយ ហើយ 37 ភាគរយទៀតមកពីប្រទេសផ្សេងទៀត។ វិស័យកាត់ដេរសម្លៀកបំពាក់ដែលជំរុញដោយការវិនិយោគដោយផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា នៅតែប្រមូលផ្តុំនៅក្នុងសកម្មភាពដែលមានតម្លៃបន្ថែមទាបដោយក្នុងនោះ រោងចក្រកាត់ដេរកម្ពុជាពាក់ព័ន្ធ នឹងដំណើរការ *កាត់ ផលិត និងតម្រឹម* (cut-make-trim)។ រចនាម៉ូដ និងផលិតកម្មកម្រិតខ្ពស់ជាងនេះ ការនាំចេញ និងការសម្រេចចិត្តផ្នែកការគ្រប់គ្រង ភាគច្រើនត្រូវបានធ្វើឡើងនៅឯទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនមេបរទេស ហើយការផ្ទេរបច្ចេកវិទ្យានៅមានកម្រិតនៅឡើយរហូតមកទល់ពេលបច្ចុប្បន្ននេះ។[27]

**ខ – ការបើក ការបិទ និងប្រតិបត្តិការរោងចក្រ៖**

យោងតាមក្រសួងពាណិជ្ជកម្ម ចំនួនរោងចក្រកាត់ដេរសម្លៀកបំពាក់និងស្បែកជើង បានធ្លាក់ចុះចំនួន 95 ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ 2016។ ការបិទរោងចក្រសុទ្ធទាំងនេះ រួមមានរោងចក្រកាត់ដេរចំនួន 88 ដែលតិចជាងមុន និងរោងចក្រ ស្បែកជើងចំនួន 7 ដែលតិចជាងមុន។ និយាយជាទូទៅ រោងចក្រចំនួន 122 បានបិទទ្វារ រីឯរោងចក្រថ្មីមានចំនួន 27 ។ ភាពខុសគ្នា រវាងរោងចក្រទាំងពីរប្រភេទនេះ គឺការបិទសុទ្ធ 95 ។[28].

រោងចក្រខ្លះក្នុងចំណោមរោងចក្រដែលបានបិទទាំងនេះ រួមមានរោងចក្រកាត់ដេរដែលបានបញ្ឈប់ប្រតិបត្តិការជាក់ស្តែងក្នុងរយៈ

[27] IMF: ពាណិជ្ជកម្មកំពុងមានការផ្លាស់ប្តូរ និងភាពពាក់ព័ន្ធរបស់ចិនសម្រាប់សេដ្ឋកិច្ច CLMV នាយកដ្ឋានអាស៊ីនិងប៉ាស៊ីហ្វិក ខែកញ្ញា ឆ្នាំ 2016 (p. 57)

[28] ក្រសួងពាណិជ្ជកម្ម មិនបានចេញតួលេខស្តីពីការបើកនិងបិទរោងចក្រពេញមួយឆ្នាំសម្រាប់ឆ្នាំ 2016 នៅពេលបោះពុម្ពផ្សាយ។ ស្ថិតិពី MoLVT ត្រូវបានដកស្រង់ដោយប្រព័ន្ធផ្សព្វផ្សាយ (Fresh News នៅថ្ងៃទី7 ខែមករា ឆ្នាំ 2017 និងភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី10 ខែមករា ឆ្នាំ2017) ស្ថិតិនេះបញ្ជាក់ថា រោងចក្រកាត់ដេរសំលៀកបំពាក់និងស្បែកជើងចំនួន 141 បានបិទទ្វារក្នុងឆ្នាំ2016 ខណៈពេលដែលរោងចក្រចំនួន 149 បានបើកទ្វារក្នុងឆ្នាំដដែល។

ពេលនោះ រីឯ រោងចក្រខ្លះបានបិទទ្វារតាំងពីមុនរយៈពេលនេះផងដែរ។ ក្រសួងបានធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យរបស់ខ្លួនដោយធ្វើចំណាត់ថ្នាក់ឡើងវិញ នូវចំនួនរោងចក្រដែលមិនមានសកម្មភាពរយៈពេលជាច្រើនខែ ហើយក្នុងករណីខ្លះ បានបិទទ្វារប៉ុន្តែមិនបានផ្តល់ការជូនដំណឹងជាផ្លូវការទេ។ គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ 2016 ចំនួនសរុបនៃរោងចក្រកាត់ដេរសម្លៀកបំពាក់និងស្បែកជើង ដែលកំពុងមានប្រតិបត្តិការពេញលេញមាន 604 ធ្លាក់ចុះពី 699 នៅចុងឆ្នាំ 2015។[29]

គេគួរកត់សម្គាល់ថា ការនាំចេញផលិតសម្លៀកបំពាក់បានបន្តកើនឡើងយ៉ាងរឹងមាំ។ ការនាំចេញរបស់វិស័យនេះ បានកើនឡើងចំនួន 10.8 ភាគរយ ក្នុងរយៈពេលប្រាំមួយខែដំបូង នៃឆ្នាំ 2016 ធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ 2015។ នេះបង្ហាញថា ការបិទរោងចក្រសុទ្ធសាធយ៉ាងច្រើន (net factory closures) គឺដោយសារតែការកែតម្រូវស្ថិតិ ជាជាងការបិទរោងចក្រជាក់ស្តែង។

## 3. ការងារ និងប្រាក់ឈ្នួល

យោងតាមក្រសួងពាណិជ្ជកម្ម ក្នុងអំឡុងពេល 6 ខែដំបូងនៃឆ្នាំ 2016 ចំនួនការងារនៅក្នុងរោងចក្រកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើងដែលបានចុះបញ្ជីសរុប មានចំនួន 610,000 នាក់ កើនឡើងចំនួន 0.6 ភាគរយ បើប្រៀបធៀបនឹងរយៈពេលប្រាំមួយខែដំបូងឆ្នាំ 2015។[30] ការចំណាយលើប្រាក់ឈ្នួលសរុប របស់ឧស្សាហកម្មនេះ បានកើនឡើងដល់ 116 លានដុល្លារអាមេរិកក្នុងមួយខែ កើនឡើងពីមធ្យមភាគ 109 លានដុល្លារអាមេរិក ក្នុងឆ្នាំ 2015។

ប្រាក់ឈ្នួលអប្បបរមាបានកើនឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ នៅក្នុងប្រទេសដែលនាំចេញសម្លៀកបំពាក់ និងស្បែកជើងធំៗជាច្រើនក្នុងតំបន់ រួមទាំងកម្ពុជាផងដែរ។ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាក្នុងឆ្នាំ 2016 ត្រូវបានកំណត់ត្រឹម 140 ដុល្លារអាមេរិកក្នុងមួយខែ ខ្ពស់ជាងប្រទេសប៉ាគីស្ថាន (US$ 124) ឡាវ (US$ 110) មីយ៉ាន់ម៉ា (US$ 85) និងតំបន់ខ្លះនៃ ប្រទេសវៀតណាម។ វៀតណាមមានប្រាក់ឈ្នួលអប្បបរមាបួនប្រភេទខុសគ្នាដោយកម្រិតខ្ពស់បំផុត គឺត្រូវបានកំណត់សម្រាប់ទីក្រុងធំៗ (US$ 154) ហើយកម្រិតទាបបំផុត (US$ 106) ត្រូវបានកំណត់សម្រាប់តំបន់ជនបទ។

**រូបទី 5៖ ប្រាក់ឈ្នួលអប្បបរមាប្រចាំខែនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់របស់ប្រទេសនាំចេញធំជាងគេចំនួន 25** (គិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ 2016)




ប្រភព៖ ការចងក្រងរបស់ ILO ដោយផ្អែកលើប្រភពជាតិ។ អត្រាប្តូរប្រាក់ពី IMF ដំណាក់ស្រង់សម្រាប់បង់ក្លាដែស និងវៀតណាម ដែលត្រូវបានយកចេញពី xe.com (ប្រើអត្រាប្តូរប្រាក់ ថ្ងៃទី 1 ខែមករា ឆ្នាំ 2016)។

ដូចកម្មករជាច្រើននៅកន្លែងផ្សេងទៀតដែរ កម្មករកម្ពុជាក៏ត្រូវបានផ្តល់ជូននូវប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែរ ពីលើប្រាក់ឈ្នួលអប្បបរមា។ ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍ទាំងនេះ រួមមានប្រាក់រង្វាន់សម្រាប់ការមកធ្វើការទៀងទាត់ប្រចាំខែ ចំនួន 10 ដុល្លារអាមេរិក និងប្រាក់ឧបត្ថម្ភសម្រាប់ធ្វើដំណើរ និងការស្នាក់នៅចំនួន 7 ដុល្លារអាមេរិក និងប្រាក់ឧបត្ថម្ភសម្រាប់អាហារចំនួន 0.5 ដុល្លារអាមេរិកសម្រាប់ម៉ោងបន្ថែម (over-time)។ ជាមធ្យម ប្រាក់ចំណូលរបស់កម្មករគឺខ្ពស់ជាងប្រាក់ឈ្នួលអប្បបរមា ទោះបីជាប្រាក់ខែគោលជាទូទៅស្មើនឹង ឬ ជិតស្មើនឹងប្រាក់ឈ្នួលអប្បបរមាក្តី។

[29] ចំនួននេះយោងទៅលើរោងចក្រនាំចេញ ដែលត្រូវបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងពាណិជ្ជកម្មតែប៉ុណ្ណោះ។ រោងចក្រម៉ៅការបន្តខ្លះ (ដែលមិននាំចេញដោយផ្ទាល់ ឬមិនចុះបញ្ជីជាផ្លូវការ) មិនត្រូវបានដាក់បញ្ចូលទេ។

[30] ផ្អែកលើមធ្យមភាគប្រាំមួយខែនៃតួលេខការងារប្រចាំខែ។

ចំណូលប្រចាំខែជាមធ្យមរបស់កម្មករកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជា បានកើនឡើងពី 145 ដុល្លារអាមេរិក ក្នុងឆ្នាំ 2014 ដល់ 175 ដុល្លារអាមេរិកក្នុងឆ្នាំ 2015 និងដល់ 190 ដុល្លារអាមេរិក ក្នុងពាក់កណ្ដាលឆ្នាំ 2016។ បើសំរួលតាមអត្រាអតិផរណា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម[31] បានកើនឡើងពី 127 ដុល្លារអាមេរិក ក្នុងឆ្នាំ 2014 ដល់ 151 ដុល្លារអាមេរិក ក្នុងឆ្នាំ 2015 និងដល់ 161 ដុល្លារអាមេរិក ក្នុងពាក់កណ្ដាលឆ្នាំ 2016។

**រូបទី 6៖ ការងារ និង ប្រាក់ឈ្នួលប្រចាំខែជាមធ្យមទូទៅ និងជាក់ស្ដែង (វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង)**




ប្រភព៖ ក្រសួងពាណិជ្ជកម្ម វិទ្យាស្ថានជាតិស្ថិតិ (NIS)

ភាគីពាក់ព័ន្ធខ្លះបានសំដែងការព្រួយបារម្ភថា ផលិតភាពរបស់វិស័យនេះមិនកើនឡើងក្នុងល្បឿនដូចកំណើនប្រាក់ឈ្នួល ជាក់ស្ដែង។ សមាគមរោងចក្រកាត់ដេរនៃកម្ពុជា (GMAC) បានអំពាវនាវឱ្យមានការផ្ដោតការយកចិត្តទុកដាក់លើផលិតភាពជាថ្មីទៀត[32] ហើយអំពាវនាវឱ្យអ្នកទិញ អនុវត្តរបៀបបញ្ជាទិញប្រកបដោយនិរន្តរភាព។ GMAC កំពុងតែពិភាក្សាជាមួយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ធ្វើ "យុទ្ធនាការផលិតភាព"។[33] នៅក្នុងអំឡុងសុន្ទរកថាតាមទូរទស្សន៍ជាតិ កាលពីថ្ងៃទី 7 ខែវិច្ឆិកា ឆ្នាំ 2016 នាយករដ្ឋមន្ត្រីកម្ពុជាបានស្នើឱ្យពង្រឹងសមត្ថភាពបច្ចេកទេសរបស់កម្មករបច្ចុប្បន្ននៅក្នុងវិស័យនេះ ដើម្បីលើកកម្ពស់ ទិន្នផល និងគុណភាព។[34]

### 4. ការវិវឌ្ឍផ្នែកគោលនយោបាយផ្សេងទៀត ទាក់ទងទៅនឹងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង

- រដ្ឋាភិបាលនឹងដំឡើងកម្រិតអត្រាដែលត្រូវបង់ពន្ធលើប្រាក់បៀវត្សរ៍ ជាថ្មីម្ដងទៀត ពីកម្រិតបច្ចុប្បន្ន 800,000 រៀល (ឬ 200 ដុល្លារអាមេរិក) ដល់កម្រិតថ្មីមួយ គឺ 1,000,000 រៀល (250 ដុល្លារអាមេរិក) នឹងចូលជាធរមានពីខែ មករា ឆ្នាំ 2017។[35] ការកែសម្រួលកម្រិតពន្ធនេះ នឹងជួយកាត់បន្ថយការជាប់កាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលរបស់ កម្មកររួមទាំង កម្មករកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ផងដែរ ដែល នេះគឺជាការ សំរួលកម្រិតអត្រាលើកទីពីរក្នុងរយៈពេលពីរឆ្នាំ។
- បន្ថែមពីលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាបានចេញសារាចរណែនាំមួយដែលបញ្ជាក់ថាប្រាក់ឧបត្ថម្ភដែលមិនមែនជាប្រាក់បៀវត្សរ៍ នឹងមិនត្រូវបានដាក់បញ្ចូលក្នុងការគណនាពន្ធលើប្រាក់បៀវត្សរ៍ប្រចាំខែទៀតទេ។[36] អត្ថប្រយោជន៍ដែលមិនត្រូវបានដាក់បញ្ចូលក្នុងការគណនាពន្ធលើប្រាក់បៀវត្សរ៍រួមមាន៖

1. ប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងការស្នាក់នៅ។
2. ប្រាក់ឧបត្ថម្ភអាហារដែលផ្ដល់ដល់កម្មករទាំងអស់ដោយមិនគិតពីតួនាទី ឬមុខតំណែង។
3. បេឡាជាតិរបបសន្តិសុខសង្គម ឬមូលនិធិសុខុមាលភាពសង្គម ដែលផ្ដល់ដល់កម្មករ/និយោជិតដោយមិនគិតពីតួនាទី និងមុខតំណែង។
4. បុព្វលាភនិងអត្ថប្រយោជន៍សម្រាប់ការធានារ៉ាប់រងសុខភាព ឬការធានារ៉ាប់រងអាយុជីវិតដែលផ្ដល់ដល់កម្មករ/និយោជិតដោយមិនគិតពីតួនាទីនិងមុខតំណែង។

---

[31] ការគណនារបស់ ILO ដោយផ្អែកលើតម្លៃ ខែធ្នូ ឆ្នាំ 2010។
[32] លិខិត GMAC ចុះថ្ងៃទី 20 ខែតុលា ឆ្នាំ 2015
[33] សេចក្ដីប្រកាសព័ត៌មាន GMAC ចុះថ្ងៃទី 24 ខែឧសភា ឆ្នាំ 2016។
[34] Fresh News (កម្ពុជា) ចុះថ្ងៃទី7 ខែវិច្ឆិកា ឆ្នាំ 2016 (http://m.freshnewsasia.com/index.php/en/localnews/38814-2016-11-07-08-53-43.html)
[35] សេចក្ដីជូនដំណឹងលេខ 048 របស់អគ្គនាយកដ្ឋានពន្ធដារ (GDT) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ចុះថ្ងៃទី 6 ខែមករា ឆ្នាំ 2015
និងរបាយការណ៍អន្តរាគមន៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងអំឡុងពេលពិភាក្សាថវិកាឆ្នាំ 2017 នៅឯរដ្ឋសភា (ថ្ងៃ 22 វិច្ឆិកា 2016)។ ច្បាប់ថវិកាឆ្នាំ 2017 របស់កម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី 22 ខែវិច្ឆិកា ឆ្នាំ 2016។
[36] សារាចរលេខ 011 របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ចុះថ្ងៃទី 6 ខែតុលា ឆ្នាំ 2016) ស្ដីពី "ការអនុវត្តកាតព្វកិច្ចពន្ធលើអត្ថប្រយោជន៍បន្ទាប់បន្សំ Fringe Benefits"

5. ប្រាក់ឧបត្ថម្ភសម្រាប់ទារកឬការចំណាយលើមជ្ឈមណ្ឌលថែទាំទារក។
6. ប្រាក់ផ្តាច់កិច្ចសន្យាឬសំណងសម្រាប់ការបញ្ឈប់ពីការងារ។

ការលើកលែងអត្ថប្រយោជន៍ ដោយមិនយកពន្ធ បែបនេះ ត្រូវបានធ្វើឡើងមួយរយៈមកហើយសម្រាប់កម្មករកាត់ដេរសម្លៀកបំពាក់និងស្បែកជើង។ កាលពីឆ្នាំកន្លងទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរស្រដៀងគ្នាមួយដើម្បីដកចេញប្រាក់ឧបត្ថម្ភដែលមិនមែនជាប្រាក់បៀវត្សរ៍ពីការគណនាពន្ធលើបៀវត្សរ៍។[37] សារាចរឆ្នាំនេះមានគោលបំណងគាំទ្រដល់អ្នកដែលមានចំណូលទាបផ្សេងទៀតក្រៅពីវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងផងដែរ។

- បេឡាជាតិរបបសន្តិសុខសង្គម (បសស NSSF) ដែលជាគម្រោងធានារ៉ាប់រងរបស់រដ្ឋាភិបាល គ្របដណ្តប់លើរបួសរបស់កម្មករ ជំងឺដែលពាក់ព័ន្ធនឹងការងារ និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការធ្វើដំណើរ ត្រូវបានអនុវត្តចាប់តាំងពីពាក់កណ្តាលឆ្នាំ 2008 (ដំណាក់ទី1)។ កាលពីថ្ងៃទី 6 ខែមករា ឆ្នាំ 2016 ការគ្របដណ្តប់ បសស ត្រូវបានពង្រីកដើម្បីដាក់បញ្ចូលសេវាថែទាំសុខភាព[38] (ដំណាក់កាលទី2) ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី1 ខែឧសភា ឆ្នាំ 2016 និងចាប់ផ្តើមពីរាជធានីភ្នំពេញ ខេត្តកណ្តាល និងកំពង់ស្ពឺ ដោយបន្តពង្រីកទៅកាន់ខេត្តផ្សេងៗទៀត។[39]
  យោងតាមរបាយការណ៍ពាក់កណ្តាលឆ្នាំរបស់ បសស ត្រឹមខែមិថុនា ឆ្នាំ 2016 បសស បានចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យនិងមណ្ឌលសុខភាពសាធារណៈចំនួន 93 (រួមទាំងគ្លីនិកឯកជនមួយចំនួនតូចផងដែរ) ដើម្បីផ្តល់សេវាថែទាំសុខភាពទាំងនេះដល់សមាជិករបស់ខ្លួន (កម្មករ/និយោជិតដែលបានទទួលការធានារ៉ាប់រង)។

[37] សារាចរលេខ 002 របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ចុះថ្ងៃទី20 ខែមករា ឆ្នាំ2015) ស្តីពី "ការអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ទាប់បន្សំ"
[38] អនុក្រឹត្យរបស់រដ្ឋាភិបាល លេខ 01 ចុះថ្ងៃទី6 ខែមករា ឆ្នាំ 2016។
[39] ប្រកាលេខ 093 របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី "ការកំណត់កាលវិភាគនិងដំណាក់កាលនៃការអនុវត្តរបបសន្តិសុខសង្គមស្តីពីការថែទាំសុខភាព"

## ឧបសម្ព័ន្ធ តារាងទី 1. ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងកម្ពុជា – សូចនាករដែលបានជ្រើសរើស

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q2 | Q3 | Q4 | 2015 | Q1 | Q2 | H1 | - | 2016 |
| 1.ទិន្នផលសេដ្ឋកិច្ច | | | | | | | | | | | | | | | |
| ផសស (% កំណើនតម្លៃពិត) | - | - | - | - | 7.1 | - | - | - | - | 7.0 | - | - | - | - | 7.0 |
| ផសស (%កំណើនតម្លៃបច្ចុប្បន្ន) | - | - | - | - | 10.0 | - | - | - | - | 8.9 | - | - | - | - | 12.0 |
| ផសស (តម្លៃបច្ចុប្បន្ន លានដុល្លារអាមេរិក) | - | - | - | - | 16 703 | - | - | - | - | 18 083 | - | - | - | - | 19 368 |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និងស្បែកជើង តម្លៃបច្ចុប្បន្ន លានដុល្លារអាមេរិក) | - | - | - | - | 1 683 | - | - | - | - | 1 915 | - | - | - | - | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និងស្បែកជើង % នៃផសស) | - | - | - | - | 10.1 | - | - | - | - | 10.6 | - | - | - | - | - |
| 2. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង | | | | | | | | | | | | | | | |
| *2a. កំណើននៃការនាំចេញសម្លៀកបំពាក់ និងស្បែកជើងសរុប* | | | | | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់និងស្បែកជើង (US$ million) [1/] | 1 464 | 1 379 | 1 625 | 1 493 | 5 960 | 1 549 | 1 602 | 1 995 | 1 681 | 6 827 | 1 773 | 1 718 | 3 491 | - | - |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | 19.7 | 9.6 | 3.6 | 11.9 | 10.7 | 5.8 | 16.1 | 22.8 | 12.6 | 14.5 | 14.5 | 7.2 | 10.8 | - | - |
| ការនាំចេញសម្លៀកបំពាក់ (US$ million)[1/] | 1 359 | 1 271 | 1 502 | 1 357 | 5 489 | 1 400 | 1 434 | 1 832 | 1 501 | 6 167 | 1 605 | 1 527 | 3 132 | - | - |
| % កំណើន (ប្រចាំឆ្នាំ) | 19.8 | 8.7 | 1.8 | 9.1 | 9.3 | 3.0 | 12.9 | 21.9 | 10.6 | 12.3 | 14.7 | 6.5 | 10.5 | - | - |
| ការនាំចេញស្បែកជើង (US$ million) | 105 | 109 | 122 | 135 | 471 | 149 | 168 | 163 | 180 | 660 | 168 | 191 | 359 | - | - |
| % កំណើន (ពីមួយឆ្នាំទៅមួយឆ្នាំ) | 19.2 | 20.1 | 33.1 | 50.6 | 30.8 | 41.7 | 54.4 | 33.6 | 33.0 | 40.0 | 12.9 | 13.8 | 13.4 | - | - |
| ការនាំចូលវត្ថុធាតុដើមសម្លៀកបំពាក់ដែលបានរក្សាទុក (US$ million) | -584 | -672 | -643 | -671 | -2 571 | -616 | -816 | -813 | -705 | -2 949 | -710 | -846 | -1 556 | - | - |
| *2b. ការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើង តាមគោលដៅសំខាន់ៗ* | | | | | | | | | | | | | | | |
| ការនាំចេញសរុប (សម្លៀកបំពាក់និងស្បែកជើង, US$ million) | 1 464 | 1 379 | 1 625 | 1 493 | 5 960 | 1 549 | 1 602 | 1 995 | 1 681 | 6 827 | 1 773 | 1 718 | 3 491 | - | - |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់និងស្បែកជើង)[1/] | 531 | 452 | 511 | 469 | 1 964 | 491 | 494 | 585 | 439 | 2 009 | 429 | 440 | 870 | - | - |
| ទៅកាន់សហភាពអឺរ៉ុប (សម្លៀកបំពាក់និងស្បែកជើង)[1/] | 533 | 559 | 674 | 639 | 2 404 | 617 | 686 | 844 | 757 | 2 904 | 793 | 777 | 1 570 | - | - |
| ទៅកាន់ពិភពលោក (សម្លៀកបំពាក់និងស្បែកជើង)[1/] | 400 | 368 | 440 | 385 | 1 593 | 440 | 422 | 566 | 486 | 1 914 | 550 | 501 | 1 051 | - | - |
| ការនាំចេញសរុប (សម្លៀកបំពាក់, US$ million)[1/] | 1 359 | 1 271 | 1 502 | 1 357 | 5 489 | 1 400 | 1 434 | 1 832 | 1 501 | 6 167 | 1 605 | 1 527 | 3 132 | - | - |

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q2 | Q3 | Q4 | 2015 | Q1 | Q2 | H1 | - | 2016 |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់)1/ | 512 | 437 | 494 | 446 | 1 889 | 462 | 461 | 557 | 408 | 1 888 | 400 | 409 | 809 | - | - |
| ទៅកាន់សហភាពអឺរ៉ុប (សម្លៀកបំពាក់)1/ | 482 | 500 | 616 | 575 | 2 173 | 546 | 600 | 768 | 670 | 2 583 | 714 | 679 | 1 393 | - | - |
| ទៅកាន់ពិភពលោក (សម្លៀកបំពាក់)1/ | 365 | 334 | 392 | 337 | 1 427 | 392 | 373 | 508 | 424 | 1 696 | 491 | 439 | 930 | - | - |
| **ការនាំចេញសរុប (ស្បែកជើង, US$ million)** | **105** | **109** | **122** | **135** | **471** | **149** | **168** | **163** | **180** | **660** | **168** | **191** | **359** | - | - |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់) | 19 | 15 | 17 | 23 | 74 | 29 | 33 | 28 | 31 | 121 | 29 | 32 | 61 | - | - |
| ទៅកាន់សហភាពអឺរ៉ុប (ស្បែកជើង) | 51 | 59 | 58 | 64 | 231 | 72 | 86 | 76 | 86 | 321 | 79 | 97 | 177 | - | - |
| ទៅកាន់ពិភពលោក (ស្បែកជើង) | 36 | 34 | 48 | 48 | 166 | 49 | 49 | 58 | 62 | 218 | 60 | 62 | 122 | - | - |
| **3. ការវិនិយោគថ្មី ការបើក និងការបិទរោងចក្រ** | | | | | | | | | | | | | | | |
| ***3a. គម្រោងវិនិយោគថ្មី*** | | | | | | | | | | | | | | | |
| **គម្រោងវិនិយោគដែលអនុម័តដោយ CIB សរុប** | **44** | **48** | **42** | **15** | **149** | **37** | **26** | **30** | **31** | 124 | **37** | **23** | **60** | - | - |
| **ក្នុងនោះ៖ គម្រោងកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង 1/** | **25** | **32** | **15** | **6** | **78** | **19** | **19** | **20** | **14** | 72 | **22** | **9** | **31** | - | - |
| គម្រោងកាត់ដេរសម្លៀកបំពាក់ | 24 | 29 | 13 | 6 | 72 | 17 | 12 | 15 | 13 | 57 | 18 | 7 | 25 | - | - |
| គម្រោងស្បែកជើង | 1 | 3 | 2 | 0 | 6 | 2 | 7 | 5 | 1 | 15 | 4 | 2 | 6 | - | - |
| **គម្រោងដែលអនុម័តដោយ CIB (US$ million)** | **446** | **382** | **626** | **150** | **1 604** | **2 873** | **255** | **279** | **513** | 3 920 | **955** | **827** | **1 782** | - | - |
| **ក្នុងនោះ៖ គម្រោងកាត់ដេរសម្លៀកបំពាក់និងស្បែកជើង (US$ million) 1/** | **135** | **200** | **86** | **30** | **452** | **72** | **80** | **84** | **141** | 377 | 86 | 42 | **128** | - | - |
| គម្រោងកាត់ដេរសម្លៀកបំពាក់ (US$ million) | 127 | 174 | 77 | 30 | 408 | 64 | 42 | 64 | 55 | 225 | 71 | 31 | 101 | - | - |
| គម្រោងស្បែកជើង (US$ million) | 7 | 27 | 9 | 0 | 44 | 8 | 38 | 20 | 86 | 151 | 15 | 11 | 26 | - | - |
| ***3b. ការបើកនិងបិទរោងចក្រ (រោងចក្រដែលបានចុះបញ្ជី)1/*** | | | | | | | | | | | | | | | |
| **រោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងសរុប (ចុងបញ្ចប់នៃរយៈពេល)** | **548** | **576** | **597** | **626** | **626** | **640** | **655** | **680** | **699** | 699 | **589*** | **604** | **604** | - | - |
| រោងចក្រកាត់ដេរសម្លៀកបំពាក់ (e. o. p.) | 488 | 515 | 532 | 558 | 558 | 572 | 585 | 607 | 626 | 626 | 526 | 538 | 538 | - | - |
| រោងចក្រស្បែកជើង (e. o. p.) | 60 | 61 | 65 | 68 | 68 | 68 | 70 | 73 | 73 | 73 | 63 | 66 | 66 | - | - |
| **ចំនួនបើកសុទ្ធសរុប (សម្លៀកបំពាក់និងស្បែកជើង)1/** | **20** | **28** | **21** | **29** | **98** | **14** | **15** | **25** | **19** | 73 | **-110*** | **15** | **-95** | - | - |
| រោងចក្រកាត់ដេរសម្លៀកបំពាក់ | 19 | 27 | 17 | 26 | 89 | 14 | 13 | 22 | 19 | 68 | -100 | 12 | -88 | - | - |

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q2 | Q3 | Q4 | 2015 | Q1 | Q2 | H1 | - | 2016 |
| រោងចក្រស្បែកជើង | 1 | 1 | 4 | 3 | 9 | 0 | 2 | 3 | 0 | 5 | -10 | 3 | -7 | - | - |
| **ការបើក (សម្លៀកបំពាក់និងស្បែកជើង)[1/]** | **22** | **33** | **25** | **29** | **109** | **14** | **16** | **26** | **19** | **75** | **12** | **15** | **27** | - | - |
| រោងចក្រកាត់ដេរសម្លៀកបំពាក់ | 20 | 31 | 21 | 26 | 98 | 14 | 14 | 23 | 19 | 70 | 10 | 12 | 22 | - | - |
| រោងចក្រស្បែកជើង | 2 | 2 | 4 | 3 | 11 | 0 | 2 | 3 | 0 | 5 | 2 | 3 | 5 | - | - |
| **ការបិទ (សម្លៀកបំពាក់និងស្បែកជើង)[1/]** | **2** | **5** | **4** | **0** | **11** | **0** | **1** | **1** | **0** | **2** | **122*** | **0** | **122** | - | - |
| រោងចក្រកាត់ដេរសម្លៀកបំពាក់ | 1 | 4 | 4 | 0 | 9 | 0 | 1 | 1 | 0 | 2 | 110 | 0 | 110 | - | - |
| រោងចក្រស្បែកជើង | 1 | 1 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 12 | 0 | 12 | - | - |
| **4. ការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង** | | | | | | | | | | | | | | | |
| **ចំនួនកម្មករកាត់ដេរសម្លៀកបំពាក់និងស្បែកជើងសរុប (រយៈពេលមធ្យម, '000)** | **539** | **561** | **576** | **581** | **564** | **597** | **616** | **635** | **643** | **623** | **628** | **592** | **610** | - | - |
| % ប្រែប្រួល (ពីមួយឆ្នាំទៅមួយឆ្នាំ) | 17.6 | 16.5 | 11.7 | 9.1 | 13.5 | 10.7 | 9.8 | 10.3 | 10.7 | 10.4 | 5.3 | -3.9 | 0.6 | - | - |
| កម្មករនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ (រយៈពេលមធ្យម '000) | 454 | 475 | 484 | 488 | 475 | 500 | 516 | 533 | 538 | 522 | 525 | 494 | 510 | - | - |
| កម្មករនៅក្នុងវិស័យស្បែកជើង (រយៈពេលមធ្យម '000) | 85 | 87 | 92 | 93 | 89 | 97 | 101 | 102 | 106 | 101 | 103 | 98 | 101 | - | - |
| **5. ប្រាក់ឈ្នួល និងតម្លៃលក់** | | | | | | | | | | | | | | | |
| **ប្រាក់ឈ្នួលអប្បបរមា (វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង, US$)** | **100[2/]** | **100** | **100** | **100** | **100** | **128** | **128** | **128** | **128** | **128** | **140** | **140** | **140** | - | - |
| **ប្រាក់ឈ្នួលប្រចាំខែជាមធ្យម (សម្លៀកបំពាក់ និងស្បែកជើង, US$)[4/]** | **137** | **145** | **152** | **146** | **145** | **164** | **174** | **184** | **178** | **175** | **187** | **193** | **190** | - | - |
| ប្រាក់ឈ្នួលប្រចាំខែជាមធ្យម (កម្មករកាត់ដេរសម្លៀកបំពាក់ US$)[3/] | 139 | 147 | 153 | 146 | 146 | 165 | 176 | 188 | 181 | 178 | 190 | 195 | 193 | - | - |
| ប្រាក់ឈ្នួលប្រចាំខែជាមធ្យម (កម្មករកាត់ដេរស្បែកជើង US$)[3/] | 127 | 137 | 149 | 146 | 140 | 157 | 165 | 166 | 165 | 163 | 173 | 184 | 179 | - | - |
| **ប្រាក់ឈ្នួលប្រចាំខែពិត មធ្យមជាក់ស្តែង (សម្លៀកបំពាក់និងស្បែកជើង គិតតម្លៃថេរ ខែធ្នូ 2010 US$)[3/ 4/]** | **121** | **127** | **131** | **127** | **127** | **143** | **151** | **158** | **152** | **151** | **160** | **162** | **161** | - | - |
| ប្រាក់ឈ្នួលប្រចាំខែពិត មធ្យមជាក់ស្តែង (សម្លៀកបំពាក់តម្លៃថេរខែធ្នូ 2010 US$)[3/ 4/] | 123 | 128 | 132 | 127 | 128 | 144 | 152 | 161 | 154 | 153 | 162 | 164 | 163 | - | - |

| | 2014 | | | | | 2015 | | | | | 2016 | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2014 | Q1 | Q2 | Q3 | Q4 | 2015 | Q1 | Q2 | H1 | - | 2016 |
| ប្រាក់ឈ្នួលប្រចាំខែពិតមធ្យមជាក់ស្តែង (ស្បែកជើង តម្លៃថេរខែធ្នូ 2010 US$)[3/ 4/] | 113 | 119 | 129 | 127 | 122 | 137 | 143 | 142 | 141 | 141 | 148 | 154 | 151 | - | - |
| **សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (រយៈពេលមធ្យម) មូលដ្ឋានខែធ្នូ 2010=100** | **113.0** | **114.5** | **115.8** | **114.7** | 114.5 | **114.2** | **115.6** | **116.8** | **117.0** | 115.9 | **117.0** | **119.1** | **118.1** | - | - |
| **អត្រាអតិផរណា (CPI រយៈពេលមធ្យម,កំណើនប្រចាំឆ្នាំ y-o-y )** | **4.6%** | **4.8%** | **4.0%** | **2.1%** | 3.9% | **1.0%** | **1.0%** | **0.8%** | **2.0%** | 1.2% | **2.5%** | **3.0%** | **2.8%** | - | - |

កំណត់សម្គាល់៖ តម្លៃបច្ចុប្បន្ននៃ ផសស អត្រាកំណើនតម្លៃពិត និងតម្លៃបច្ចុប្បន្ន (real and nominal growth rate) សម្រាប់ឆ្នាំ 2016 គឺការព្យាកររបស់ IMF (មាត្រា IV នៃរបាយការណ៍របស់ IMF ស្តីពីកម្ពុជា ខែវិច្ឆិកា ឆ្នាំ 2016)

1/ រួមបញ្ចូលទាំងវាយនភ័ណ្ឌ។

2/ ចូលជាធរមានថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2014។

3/ ផ្អែកលើក្រសួងពាណិជ្ជកម្ម រោងចក្រដែលមានប្រតិបត្តិការតែប៉ុណ្ណោះ។ ទិន្នន័យមិនរួមបញ្ចូលបុគ្គលិកបរទេសដែលធ្វើការក្នុងការិយាល័យ និងអ្នកគ្រប់គ្រងបរទេស ទេ។

4/ នៅតម្លៃខែធ្នូ ឆ្នាំ 2010។

*/ កត់សម្គាល់ថា សមាមាត្រដ៏ធំមួយនៃការបិទរោងចក្រដែលបានកត់ត្រា គឺជាលទ្ធផលនៃការចុះត្រួតពិនិត្យ និងធ្វើចំណាត់ថ្នាក់ឡើងវិញរបស់ក្រសួងពាណិជ្ជកម្ម ទៅលើរោងចក្រដែលកំពុងមានប្រតិបត្តិការ និងរោងចក្រដែលបិទជាបណ្តោះអាសន្ន ដែលរួមបញ្ចូលរោងចក្រដែលគ្មានសកម្មភាពខ្លះ ដែលបានបិទទ្វារដោយមិនបានជូនដំណឹងដល់ក្រសួង។

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាណិជ្ជកម្ម ធនាគារជាតិនៃកម្ពុជា, IMF និងការគណនាដោយបុគ្គលិក ILO

## ព័ត៌មានទំនាក់ទំនង

មន្ត្រីសម្របសម្រួលអង្គការអន្តរជាតិខាងការងារសម្រាប់កម្ពុជា
មជ្ឈមណ្ឌលភ្នំពេញ អគារ I ជាន់ទី២ កាច់ជ្រុងមហាវិថីព្រះសីហនុ (២៧៤)
& សម្ដេចសុធារស (៣), រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +855 23 220 817
គេហទំព័រ៖ www.ilo.org/asia
អ៊ីមែល៖ huot@ilo.org



រក្សាសិទ្ធិ © អង្គការអន្តរជាតិខាងការងារ 2016


កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT


*ការបោះពុម្ពផ្សាយនេះត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌនៃនិយាមការងារ នៅក្នុងកម្មវិធីសង្វាក់ផ្គត់ផ្គង់សកលដែលហិរញ្ញប្បទានដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងដោយ GIZ ក្នុងនាមរដ្ឋាភិបាលអាល្លឺម៉ង់។ កម្មវិធីនេះត្រូវបានផ្តួចផ្តើមឡើងក្នុងផ្នែកមួយនៃភាពជាដៃគូជាថ្មីរវាងក្រសួងសហប្រតិបត្តិការអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ) និងអង្គការអន្តរជាតិខាងការងារ (ILO)។ ការទទួលខុសត្រូវលើទស្សនៈដែល បានសំដែងនៅក្នុងឯកសានេះ គឺស្ថិតលើអ្នកនិពន្ធ ហើយទស្សនៈដែលបានលើកឡើងនៅក្នុងឯកសារនេះ មិនមែនជាការអនុម័ត របស់អង្គការ ILO ឬ រដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ឡើយ ។*